# អាគ្រាតភ្លៀងធំ

ប្រាវ....ព្រះភិរុណបានបង្កើនអនុភាព។

ភីណាដកដៃពី screenទូរសព្ទហើយប្តូរទឹកមុខ។តាមរយៈទ្វារកញ្ចក់ពណ៌សថ្លា រលកវាំងននសូត្រទន់ល្មើយត្រូវបានរសាត់បោកបំប៉ើងដោយកម្លាំងខ្យល់។

«ដូចរឿងខ្មោចអញ្ចឹង!»

គិតផង ស្រីតូចលែងដៃពីឧបករណ៍ទូរសព្ទបញ្ចប់ការកម្សាន្ត ហើយឃើតៗក្រោកមកទាញទ្វារកញ្ចក់បិទវិញ។

ចិត្តហាក់ ថប់បារម្ភចម្លែក។ពិភាល់អ្វីមួយដែលមិនប្រក្រតី តាមលងបន្លាចចិត្តស្រីតូចជានិច្ចជាកាលរាល់ពេលបងប្រុសមិននៅ ហើយយប់នេះទៀត មេឃភ្លៀងដូចជាខឹងនឹងភពផែនដី។

ទ្រនិចនាឡិកាចង្អុលដល់ម៉ោង១២នៅលើជញ្ជាំងចំពីមុខនារី ហាក់កំពុងឌីដងឲ្យក្រសែភ្នែករលើបក្រឡង់របស់នាង។

គេងៗ គេងៗ គេងលក់បាត់ខ្លាច!ព្រឹកឡើងបាត់ខ្វល់!

ភីណារមែងតែងគិតការងាយៗស្រាប់ហើយ។ នាងថយមករកគ្រែដ៏ទន់ល្មើយ ហើយប្រាសខ្នងទាញភួយសម្លីដណ្តប់ផុតពីក្បាលនិងចុងជើង។

ពិតមែនហើយ....ខ្លាចខ្មោចគឺជាចំណុចខ្សោយរបស់នាង។

ខ្មោចមិនខ្លាចទៅខ្លាចស្អីវិញ?

ស្រីតូចគិតទាំងបិទភ្នែកបង្ខំត្រចៀកអោយឈប់ដឹងឈប់លឺ។

ដោយចាប់កំណើតក្នុងត្រកូលគហបតីដែលត្រូវបានឪពុកម្តាយចែកឋានចោលតាំងពីបាន១៤ឆ្នាំ ស្រីស្រស់ដែលពេលនេះជាយុវវ័យលេចធ្លោជាងគេនៅសង្កាត់លេខមួយ ត្រូវបានចិញ្ចឹមបីបាច់ដោយបងប្រុសបង្កើតជាពាណិជ្ជករដ៏ជោគជ័យម្នាក់។ ប្រវត្តិបុរសអភិជនម្ចាស់ភូមិគ្រឹះស៊ីមស្ដៃមួយនេះ មិនដែលត្រូវបានគេបើកទូលាយឡើយ...តែគេគ្រាន់តែដឹងថា គាត់ឧស្សាហ៍ធ្វើដំណើរទៅបរទេសញឹកញយពុំសូវមានវត្តមាននៅក្នុងផ្ទះ ភាគច្រើន អ្នកស្រី

កុលាបភរិយារូបល្អរបស់គាត់ និងតរុណីភីណាប្អូនស្រីតែមួយគត់របស់គាត់ជាអ្នកស្នាក់នៅថែទាំ ។

អឺ មីងអួន? មីងម៉ាប់?

នាងហៅផង ឈានចុះជណ្ដើរមកតាំងៗ ដោយសារការសម្ងំក្នុងភួយប្រឆាំងនឹងភាពភ័យខ្លាចមិនបានជួយនាងឲ្យគេងលក់ដូចបំណង។

ទោះជាហៅច្រើនដងហើយ ក៏នៅតែគ្មានចម្លើយតប។

ស្របពេលបោះជំហានមកដល់បន្ទប់ទទួលភ្ញៀវធំជាន់ខាងក្រោម វ៉ាក់អើនឹងស្ត្រីម្នាក់កំពុងអង្គុយបែរខ្នងមើលទូរទស្សន៍ធ្វើវាហី។ ទោះបីសំឡេងទូរទស្សន៍នោះបិទស្ទើរតែមិនចង់ឮ ប៉ុន្តែភីណាមើលឃើញរូបរាងខ្មោចអសុរកាយបង្ហាញច្បាស់ទែងលើអេក្រង់ដ៏ធំនោះ ធ្វើឲ្យនាងកាន់តែសៅហ្មងសម្លក់ត្មែរទៅរកស្ត្រីជាបងថ្លៃដែលកម្រនិយាយត្រូវចិត្តនាង។ នាងដើរហួសគាត់ទៅ តម្រង់រកបន្ទប់បាយដើម្បីបន្តស្វែងរកមនុស្សចំណាស់ពីរបីនាក់ដែលនាងបានហៅរកតាំងពីជាន់ខាងលើ។ មកដល់បន្ទប់បាយដែលគ្មានសូម្បីតែស្រមោលមនុស្សម្នាក់ តរុណីដើរបណ្តើរស្រែករកបណ្តើររហូតដល់បន្ទប់គេងរបស់អ្នកបម្រើ។ ធីតាលើកដៃគោះទ្វារតុៗប្រណាំងនឹងសន្ទឹកគ្រាប់ភ្លៀង។

-មីងអួន! មីងម៉ាប់! ស្ងាត់ច្រៀបគ្មានអ្នកណាឆ្លើយតបនឹងនាងសូម្បីមួយអ៊ឹះទេ។ ដោយសារតាមធម្មតាមនុស្សម្នាក្នុងផ្ទះកម្រមាននរណាហ៊ានជំទាស់ចិត្តខ្លួន កាលដែលស្រីតូចខំចុះមកតាមដល់ទីស្នាក់អាស្រ័យហើយក៏គ្មានឃើញអ្នកណាចេញមកតបនឹងបទបញ្ជាទៀត ធ្វើឲ្យតរុណីត្រកូលហង្សកាន់តែកើតក្តៅចិត្ត។ នាងស្រែកហៅផងគោះទ្វារផងបន្តរហូតដល់ហត់ទើបឈប់។

ភ្លៀងកាន់តែបង្កើនសូរសំឡេងដែលអមមកជាមួយស្នូរផ្គរស្ទើររហែកមេឃ។ ធីតាងាកទៅរកបន្ទប់សូហ្វ៍រឡាននៅឯជ្រុងចុងគេបំផុតនៃអគារផ្ទះក្រោមនេះ។ នាងហៀបនឹងបោះជំហានទៅដែរ ប៉ុន្តែគិតទាន់មកវិញថា កណ្ដាលអាធ្រាត្រទៅហើយ ទៅគោះទ្វាររកអ្នកបម្រើប្រុសមានអីសមរម្យទៅ?

...នាងដើរបកត្រឡប់មកបន្ទប់ធំវិញ ហើយដាក់បង្គុយក្រពាត់ដៃលើសាឡុងដោយទោមនស្ស។ អ្នកស្រីកុលាបដ៏មានរូបឆោមលោមពណ៌បែរមកសម្លឹងប្អូនថ្លៃស្រី ដែលរក្សាភាពមិនសប្បាយចិត្តលើផ្ទៃមុខ។ អ្នកស្រីវ័យក្មេងមិនទាន់ថាយ៉ាងណាផង ភីណាបន្លឺឡើងមុនដោយអាការរអ៊ុះៗ៖

-ដេកៗៗៗៗ! ផ្ទះធំល្វឹងដូចផ្ទះខ្មោចអញ្ចឹង។ រកតែមនុស្សម្នាក់មកប្រើក៏អត់!

ស្ត្រីជាបងថ្លៃដឹងថាការបន្ទោសអ្នកបម្រើ ឬដាស់គេមកប្រើទាំងយប់អាធ្រាត្រមិនមែនជារឿងត្រឹមត្រូវទេ ប៉ុន្តែគាត់ក៏នៅតែរក្សាភាពស្ងាត់ស្ងៀមមិនទាន់មានប្រតិកម្មថាយ៉ាងណាមកកាន់ប្អូនថ្លៃស្រីឡើយ។ ភីណានិយាយបន្ថែមរឹង៖

- បងកុសលក៏អញ្ចឹងដែរ ប្រាប់ថាទៅតែ២យប់ទេ ឥឡូវនេះលើសមួយថ្ងៃហើយ! ផ្ទះសុទ្ធតែមនុស្សស្រី!

អ្នកស្រីកុលាប លូកមាត់ឃាត់សំដីប្អូនថ្លៃស្រី៖

- ស្អែកបងប្រុសឯងត្រឡប់មកវិញហើយ...។

ភីណាមិនទាន់ស្រាយភាពមួហ្មងបាននៅឡើយ នាងរអ៊ូ៖

-គាត់ក៏ដឹងដែរ...នៅផ្ទះមានតែប្រពន្ធ និងប្អូនស្រី នៅតែដើរចោលបាត់ៗ ការងារអី? ឲ្យគេទៅជំនួសទៅ ដើរឆ្ងាយពីផ្ទះយ៉ាងនេះ មិនចេះបារម្ភពីអ្នកផ្ទះសោះ។ គង់តែមានថ្ងៃណាមួយខ្ញុំទៅនៅផ្ទះលោកយាយនៅខេត្តវិញ។ ចាំមើលបងកុសលហ៊ានដើរចោលផ្ទះឲ្យអ្នកបងនៅម្នាក់ឯងអញ្ចឹងទៀតអត់?

អ្នកស្រីវ័យក្មេងនៅស្ងៀមមិនតបមួយម៉ាត់...ភីណាទឹកមុខក្រញូវសម្លឹងទៅតំណក់ទឹកដែលស្រក់ខាងក្រៅបង្អួចកញ្ចក់មិនដាច់ នាងរអ៊ូដោយមួហ្មង៖

-ភ្លៀងទៅ...ភ្លៀងដល់ព្រឹកតែម្តងទៅ មិនបាច់រាំងទេ...។

អ្នកស្រីវ័យក្មេងងាកមកសម្លឹងប្អូនស្រីថ្លៃ គាត់សម្រួលទឹកមុខពោលទៅកាន់នាង៖

-អូនឯងហៅរកមីងអួន មីងម៉ាប់ធ្វើអី?។

នៅតែអង្គុយនៅតែខឹងអញ្ចឹង ភីណាតបវិញភ្លាម៖

-គឺគេងមិនលក់....ចង់ធ្វើអីញុំាលេងកំដរមាត់ហ្នឹង...!

ស្ត្រីជាបងថ្លៃនិយាយវិញទាំងស្ងាបហ៊ាមៗ៖

-អញ្ចឹងចង់ញុំាអី? ចាំបងធ្វើឲ្យក៏បាន!

នារីទម្រើសទាញខ្នើយមកឱបជាប់ប្រាណ ហើយនិយាយដោយក្អិកក្អក់៖

-អត់ទេ! ខឹងពេកលែងឃ្លានហើយ!

អ្នកស្រីវ័យក្មេងហួសចិត្ត តែនេះឯងជាចរិតរបស់ភីណា។ គាត់ញាក់ចិញ្ចើមរបៀបខ្ជិលខ្វល់ងាកទៅរកទូរទស្សន៍វិញ បម្រុងថាចុចបិទក្រោកទៅសម្រាកក្នុងពេលដែលគ្រាប់ភ្លៀង និងផ្គរលាន់ពីក្រៅផ្ទះ បង្កជាសព្ទសំឡេងគួរព្រឺព្រួច កណ្ដាលស្ងៃរាត្រីស្ងាត់ជ្រងំ។

ស្នូរជើងមនុស្សរត់ឱបៗនៅជាន់ខាងលើបានបង្អាក់ស្ត្រីអភិជន ដោយធ្វើឲ្យនាងប្រែទឹកមុខទៅជាផ្ទៀងស្ដាប់ ហើយរេគ្រាប់ភ្នែកមកបញ្ជាក់សួរភីណាថា តើនាងបានឮដូចគ្នាដែរឬយ៉ាងណា?។ ច្បាស់ក្រឡែត ទោះបីជាភ្លៀងខាងក្រៅផ្ទះខ្លាំងសន្ធាប់យ៉ាងណា ក៏នារីទាំងពីរដែលកំពុងអង្គុយទល់មុខគ្នាកណ្ដាលបន្ទប់ទទួលភ្ញៀវធំល្វឹងល្វើយនេះ នៅតែមានអារម្មណ៍ថាឯជាន់ខាងលើពិតជាមានស្នូរជើងមនុស្សរត់ច្បាស់ណាស់។

ពេលងាកមកមើលមុខប្អូនថ្លៃ ហើយក៏ប្រទះឃើញភីណាបង្ហាញអាការស្លេកស្លាំងសម្លឹងរកគាត់វិញនោះ ស្ត្រីជាបងងើបមុខសម្លឹងទៅរកជាន់ខាងលើ។ តាមធម្មតាប្រសិនបើគ្មានភារៈបោសសម្អាត ឬត្រូវបានហៅរកនោះទេ គ្មានអ្នកបម្រើណាម្នាក់ត្រូវបានអនុញ្ញាតឲ្យឡើងត្រេងត្រាងនៅជាន់ខាងលើនោះដាច់ខាត ពិសេសរឹតតែវីវរនោះគឺភីណាដឹងថាមនុស្សទាំងពីរដែលនាងបានហៅរក កំពុងបិទគន្លឹះទ្វារដេកលក់ដូចត្រូវសណ្ដំនៅអាគារខាងក្រោយទៅហើយ។

នាងក្រមុំរូបនេះពោលសួរដាច់ៗ របៀបភិតភ័យ៖

-អ្នកបង...អ្នក...ណានៅ...ខាងលើ?...អ្នកណា...?

សភាពបារម្ភពេញប្រៀបលើផ្ទៃមុខអ្នកស្រីវ័យក្មេង…គាត់ដៀងភ្នែកប្រឹងផ្ទៀងត្រចៀកស្តាប់ដោយប្រុងប្រយ័ត្ន…ស្ងាត់ច្រៀប…ក្រៅពីសូរគ្រាប់ភ្លៀងខាងក្រៅផ្ទះ មិនមានឮអ្វីទៀតសោះ គាត់តបទៅកាន់ភីណាវិញតិចៗ៖

-អត់ទេ! លែងឮអីហើយ!

ភីណាស្ទុះក្រោកភ្លែតមកដាក់បង្គុយកៀកនឹងបងថ្លៃដោយអាកប្បកិរិយាភិតភ័យ…នាងពោលដោយភ្នែកក្រឡឹបក្រឡាប់របៀបភ័យខ្លាច៖

-អត់ទេ!…អម្បាញ់មិញខ្ញុំឮសូរជើងមនុស្ស សូរជើងមនុស្សច្បាស់ណាស់…នៅជាន់ខាងលើពិតមែន! អ្នកបង អ្នកបងឮទេ?

អ្នកស្រីនៅរក្សាភាពស្ងៀមស្ងាត់ មិនមានតបមួយម៉ាត់ក៏ពិតមែន ប៉ុន្តែក្នុងចិត្តគាត់កំពុងខ្វល់ខ្វាយស្រេចទៅហើយ អម្បាញ់មិញ…សូរជើងមនុស្សរត់នៅឯជាន់ខាងលើនោះក៏គាត់បានឮដែរ ប៉ុន្តែមួយខណៈក្រោយក៏ស្រាប់តែបាត់ទៅវិញ បើទោះជាត្រចៀកស្តាប់ច្រឡំ ក៏ស្តាប់ច្រឡំតែម្នាក់ប៉ុណ្ណោះ មិនអាចស្តាប់ច្រឡំដូចៗគ្នាទាំងពីរនាក់យ៉ាងនេះទេ។

អ្នកស្រីវ័យក្មេងរេភ្នែកសម្លឹងភូមិគ្រឹះធំទូលំទូលាយដែលស្ងាត់ជ្រងំដោយអារម្មណ៍ច្របូកច្របល់។ មធ្យោបាយល្អបំផុតគឺត្រូវឡើងទៅខាងលើមើលទើបដឹងថាយ៉ាងណា។ គាត់ស្ទុះក្រោកពីសាឡុង តែត្រូវភីណាតោងដៃជាប់៖

-អ្នកបងគិត…គិតទៅណា?

អ្នកស្រីកុលាបប្រឹងរក្សាស្មារតីរឹងប៉ឹងតបនឹងប្អូនស្រីថ្លៃតាមសម្រួល៖

-នៅហ្នឹងហើយ! បងឡើងទៅមើល!

ភីណាក្រោកភ្លាមដោយអាការភិតភ័យ នាងពោលដោយទឹកមុខអល់អែក៖

-ខ្ញុំ…ខ្ញុំ…ខ្ញុំទៅដែរ!

នារីរូបស្អាតទាំងពីររំកិលខ្លួនសន្សឹមៗសំដៅទៅជាន់ខាងលើ…ដោយម្នាក់ខំរក្សាភាពនឹងន ឯម្នាក់ទៀតមានអាការភ័យព្រួយញ័រចំប្រប់។ បាតជើងប៉ះដល់កម្រាលព្រំអារ៉ាប់ដ៏មានតម្លៃ អ្នក

ស្រីកុលាបបញ្ឈប់ជំហាននៅឯមាត់ជណ្ដើរ ហើយរភ្នែកសម្លឹងបរិវេណផ្ទៃបន្ទប់ជុំវិញខ្លួនដែលធំល្វឹងល្វើយ និងស្ងាត់ច្រៀបមិនឮសូម្បីខ្យល់ដង្ហើមខ្លួនឯង។

ឃើញអាការម៉ត់ចត់របស់ស្ត្រីដែលមានអាយុច្រើនជាងខ្លួនមិនដល់៥ឆ្នាំនោះ ភីណាលូកដៃតោងបងថ្លៃវ័យក្មេងជាប់ក្នុងបំណងសម្រាលភាពភ័យខ្លាចរបស់ខ្លួន។ ទោះយ៉ាងណា នាងបែរជាចាប់អារម្មណ៍ភ្លាមៗថាត្រចៀកហាក់ឮសូរសំឡេងមនុស្សជជែកគ្នារអ៊ុះៗច្បាស់ណាស់។ នាងបង្វិលគ្រាប់ភ្នែកសម្លឹងជុំវិញខ្លួនដោយភិតភ័យ ហើយចាប់កំភួនដៃបងថ្លៃស្រីតឹងជាងមុនទាំងមាត់ពោលដោយញាប់ញ័រ៖

-មនុស្ស...មនុស្សមកពីណា? អ្នកបងឮ...ឮសំឡេងមនុស្សប្រុសនិយាយគ្នាអត់?...ឮអត់?

សំឡេងលាន់រអ៊ុះៗ ប្រៀបបីដូចជាមនុស្សប្រុសពីរនាក់កំពុងជជែកគ្នាខ្សឹបខ្សៀវ ពិតជាកំពុងហើរមកប៉ះសោតាអ្នកស្រីវ័យក្មេងមែន។ នាងមិនស្ដីតបនឹងសំណួរ ប៉ុន្តែជៀងភ្នែកសម្លឹងទៅកាន់បន្ទប់វត្ថុបុរាណដែលនៅខាងស្ដាំដៃ។... សំឡេងមនុស្សរអ៊ុះៗពិតជាលាន់ឮចេញមកពីបន្ទប់នោះច្បាស់ណាស់។ ក្នុងមួយវិនាទីនោះ ភីណាប្រាកដចិត្តថា ពិតជាមានមនុស្សលួចចូលទៅជជែកគ្នាស្ងាត់ៗក្នុងនោះ ទោះបីមិនដឹងថានោះជាអ្នកណាក៏ដោយ។ ផ្ទុយទៅវិញ អ្នកស្រីវ័យក្មេងបែរជាគិតខុសស្រលះពីនាងក្រមុំយើង។

-ចោរចូលមកលួចវត្ថុបុរាណ?

ប្រយោគនេះខ្លីតែក៏ល្មមឲ្យភីណាភ័យស្ទើរនឹងលោះព្រលឹង។ តើវត្ថុមានតម្លៃទាំងឡាយក្នុងបន្ទប់នោះ ជាដើមហេតុក្នុងការបង្កសំឡេងចម្លែកកណ្ដាលអធ្រាត្រ? ប៉ុន្តែទ្វារបន្ទប់បិទជិតដូចធម្មតា បើចោរលួចចូលមកមែន តើចូលមកតាមណាទៅ?

អ្នកស្រីជាបង ឈានជើងទៅកាន់ទីនោះយឺតៗ ដោយទ្រូងលោតញាប់ស្មេរ ចំណែកនាងក្រមុំភីណាក៏ចេះតែដើរតាមពីក្រោយបងថ្លៃយឺតៗដោយភាពភ័យខ្លាចកំពុងមានប្រសិទ្ធភាពលើរាងកាយ។ នាងសម្លឹងផ្ទៃទៅកាន់ទ្វារបន្ទប់វត្ថុបុរាណដែលអ្នកស្រីវ័យក្មេងកំពុងតម្រង់ទៅទាំងវាចាយឺតៗតែញាប់ញ័រ៖

-សំឡេងចេញមកពីបន្ទប់វត្ថុបុរាណនោះមែនអ្នកបង!

អ្នកស្រីវ័យក្មេងបន្តជំហានចូលកាន់តែកៀកមាត់ទ្វារបន្ទប់...សំឡេងមនុស្សជជែកគ្នាក៏លាន់កាន់តែច្បាស់ប៉ះសោតាទាំងទ្វេ...។ ម្តងនេះលែងស្រពិចស្រពិលទៀតហើយ ខាងក្នុងបន្ទប់ប្រាកដជាមានមនុស្សពិតណាស់ អ្នកស្រីកុលាប ប្រឹងតាំងស្មារតីឲ្យនឹងនជាងមុន ទើបវាចាសួរស្រ្រួយស្រែសះ

-អ្នកណានៅខាងក្នុង?

សួរសំឡេងរអ៊ុះៗអម្បាញ់មិញ ស្រាប់តែរលត់បាត់ភ្លាមវិញមួយរំពេច...ស្ងាត់ច្រៀប គ្មានឮសំឡេងអ្វីតបមកវិញសោះ។ អ្នកស្រីវ័យក្មេងក៏ទទួលអារម្មណ៍ថាព្រឺព្រួចណាស់ដែរ គាត់លូកដៃចាប់យកចង្កៀផ្កាពណ៌សដែលតាំងលំអលើតុខ្ពស់មុខបន្ទប់មកកាន់ជាប់នឹងដៃ ដោយអាការប្រុងប្រយ័ត្ន រួចបន្តនូវសំណួរទីពីរ ៖

-អ្នកណា?

ស្ងាត់ច្រៀប...សូរដកដង្ហើមបន្តិចក៏មិនមានឮផង។ ស្នូរគ្រាប់ភ្លៀងឯណោះទេ ដែលកាន់តែសន្ធាប់គួរឲ្យព្រឺព្រួច។ អ្នកស្រីកុលាបលូកដៃកាន់លើប្រអប់សោទ្វារទាំងបេះដូងលោតខុសចង្វាក់ មុនពេលប្រើកម្លាំងរុញទ្វារទៅក្នុងយ៉ាងខ្លាំងជាមួយប្រយោគសំនួរដែលញ័រទទ្រើកៈ

-អ្នកណា...?

ទ្វារបន្ទប់របើកទៅក្នុងខ្ទាក...

កណ្តាលសភាពងងឹតស្លុបក្នុងបន្ទប់វត្ថុបុរាណ ស្រាប់តែមានឮសូរដង្ហើមមនុស្សពីរនាក់ច្បាស់ណាស់។ មិនបង្អង់អ្នកស្រីរាវចុចកុងតាក់ភ្លើង។ ភ្លើងភ្លឺចែស...បង្ហាញផ្ទៃបន្ទប់ ដែលធំទូលាយពោរពេញទៅដោយវត្ថុបុរាណតាំងលម្អរាប់សិបមុខ ប៉ុន្តែអត់មានស្រមោលមនុស្សម្នាក់ទេ។ អ្នកស្រីសម្លឹងទៅទ្វារខាងមុខរានហាលដែលកំពុងចំហនៅឡើយ...គឺទីនោះហើយដែលកំពុងខាបយកព្រលឹងព្រលះនារីទាំងពីរនេះឲ្យរន្ធត់ស្ទើរចាកចេញពីរាងកាយ។ អ្នកស្រីកុលាបបើកភ្នែកគ្រលួងសម្លឹងមនុស្សពីរនាក់ដែលគ្របអាវភ្លៀងខ្មៅពីលើដល់ក្រោម ពាក់ម៉ាសបិទបាំងផ្ទៃមុខឈរបង្ហាញខ្លួននៅរានហាលខាងមុខនោះ លើដៃមានកាន់ពូថៅម្នាក់មួយផង។ ទិដ្ឋភាពដ៏គួរឲ្យរន្ធត់កណ្តាលអធ្រាត្រ បានរុញឲ្យចង្កៀផ្កាលើដៃរបស់អ្នកស្រីវ័យក្មេងត្រូវរបូតធ្លាក់ទៅលើកម្រាលឥដ្ឋលាន់ខ្ទាយ។

អ្នកស្រីកុលាបភ្លាត់មាត់ ស្រែកអស់ទំហឹង៖

-ចោរ…ចោរ…! ជួយផង…ជួយផង!

ស្ត្រីទាំងពីរបែរក្រោយរត់យ៉ាងលឿនតម្រង់មកកាន់មាត់ជណ្ដើរ។ ភីណារត់រហ័សជាងបងថ្លៃបន្តចុះជណ្ដើរទៅជាន់ខាងក្រោម តែអ្នកស្រីកុលាបវិញមិនអាចរត់បានរហ័សដូចភីណាឡើយ។ អាវរាត្រីដ៏វែង និងស៊ុលគយុលពីរបីជាន់របស់គាត់ ចេះតែជាឧបសគ្គដែលបណ្ដាលឲ្យគាត់រត់យឺតទៅៗ។ មកដល់មាត់ជណ្ដើរគាត់ស្ទុះចុះទៅខាងក្រោម…ប៉ុន្តែជំហានទីពីរបែរជាត្រូវទាក់ជើងនឹងអាវរាត្រីគ្រប់ពីក្រៅពណ៌សភ្លឺបណ្ដាលឲ្យរាងកាយតូចច្រឡឹងរបស់អ្នកស្រីរូបស្អាតបាត់ជំហរដួលរមៀលតុកៗតាមចំនួនកាំជណ្ដើររហូតដល់ជាន់ខាងក្រោម។ ម៉ាំង!

ភីណាបែរក្រោយរឹងហើយឈរស្រឡាំងកាំង សម្លឹងរាងកាយបងថ្លៃដែលល្បីថាមានរូបល្អផ្ដាច់គេ ពេលនេះកំពុងដេកស្ងៀមក្បែរជើងសាឡុងគ្មានកម្រើក។ ទោះមិនបានឃើញគ្រាប្រថុចញ៉ុចនោះ តែនាងយល់ថាស្ត្រីជាបងប្រាកដជាបានរមៀលមកដល់ខាងក្រោម ហើយបោកទង្គិចយ៉ាងដំណំទៅនឹងជើងសាឡុងដែកលាន់សូរម៉ាំង គួរឲ្យព្រឺព្រួច។

អស់ពីភាន់ភាំង ភីណាលាន់មាត់ស្រែកដោយរន្ធត់៖

-អ្នកបង!…អ្នកបង?

នាងក្រមុំសម្លឹងទៅរាងកាយស្ដូកស្ដឹងគ្មានកម្រើករបស់បងថ្លៃដែលនៅចំពោះមុខទាំងញាប់ញ័រក្នុងចិត្ត។ ទោះចង់មិនចង់ នាងចាំបាច់ត្រូវដើរចូលទៅក្បែរគាត់យឺតៗ រួចអង្គុយចុះយ៉ាងរហ័ស អង្រួនផង មាត់ស្រែកហៅដោយតក់ស្លុតផង៖

-អ្នកបង!…អ្នកបង! អ្នកបងយ៉ាងម៉េចហើយ?

ភាគទី២

អ្នកស្រីវ័យក្មេងនៅស្ងៀមគ្មានកម្រើកលើកកម្រាលព្រំ។ មាត់ និងច្រមុះគាត់ហូរឈាមរឹមៗគួរឲ្យសង្វេគណាស់។ ភីណាលូកដៃស្ទាបដង្ហើមបងថ្លៃស្រីដោយក្ដីរន្ធត់… នាងក៏ដឹងថា គាត់លែងដកដង្ហើមទៅហើយ។ ស្រីក្រមុំស្ទុះថយឆ្ងាយពីសាកសពទាំងញ័រសព្វអស់សារពាង្គកាយ។ នាងឈរញ័រទទ្រើក សម្លឹងស្ត្រីជាបងថ្លៃពីចម្ងាយ…ជាមួយសំណួរនិងភាពឆ្លេឆ្លារុករានទន្ទ្រានចិត្ត ធ្វើម៉េចទៅ? ឲ្យនាងធ្វើយ៉ាងម៉េចទៅ?

សន្ធឹកព្រះភិរុណ នៅតែលាន់យ៉ាងខ្លាំងក្លាខាងក្រៅផ្ទះ។ នាងក្រមុំយំសស្រាក់ស្ទុះមកលើកទូរសព្ទដើម្បីចុចរកជំនួយ ទូរសព្ទត្រូវផ្ដាច់ពីពេលណាក៏មិនបានដឹងដែរ...នាងបោះទូរសព្ទចោលយ៉ាងរហ័ស ចិត្តនឹកឃើញដល់ទូរសព្ទដៃ ដែលនៅឯបន្ទប់ដេកជាន់ខាងលើ។ នាងស្ទុះមកកាន់ជណ្ដើរបំណងឡើងទៅរកទូរសព្ទ ប៉ុន្តែឈានបានប្រមាណពីរជំហានប៉ុណ្ណោះ នាងត្រូវនៅទ្រឹងពីមុខសាកសព បងថ្លៃស្រីដែលស្លូកស្លឹងពីមុខជណ្ដើរ។ នាងងើយមុខសម្លឹងទៅជាន់ខាងលើដោយញ័ររន្ធត់ចិត្ត។ នាងក៏នឹកឃើញភ្លាមដែរដល់បុរសប្លែកមុខពីរនាក់នោះ។ ភីណាថយក្រោយក្រាកៗទាំងញ័ររន្ធត់។

តរុណីសម្លឹងសភាពស្ងាត់ជ្រងំជុំវិញខ្លួនទាំងអារម្មណ៍ភ័យខ្លាចឡើងៗ។ នាងស្ទុះមករកអាគារអ្នកបម្រើដែលនៅវាងពីក្រោយបន្ទប់អាហារ។ ដូចកាលពីមុននេះបន្តិចដែរ ស្ត្រីទាំងពីរគ្មានអ្នកណាម្នាក់ឆ្លើយតបទេ កុំថាឡើយដល់ក្រោកមកបើកទ្វារ ដូចនេះនាងបន្តទៅកាន់បន្ទប់សូហ្វ័រឡាន។ ពេលនេះភីណាអរព្រើតព្រោះបន្ទប់មិនបានចាក់សោទេ នាងអាចឃើញពូសួសដេកផ្ងារចង្ក្រាងលើគ្រែក្បែរបង្អួចហាក់មិនរវល់នឹងភ្លៀងផ្គរសឹងរហែកមេឃនោះឡើយ។នាងស្រែកហៅដោយតក្កមា៖

-ពូសួសៗៗ

ចម្ងាយជិតសែនជិតដល់ថ្នាក់នេះហើយ បុរសនោះគ្មានប្រតិកម្មសូម្បីតែកម្រើកតិចតួច ធ្វើឲ្យស្រីតូចដែលភ័យ ស្លន់សុខចិត្តលូកដៃទៅអង្រួនគាត់តែម្ដង។

"គាត់ក៏ស្លាប់បាត់ដែរដឹង! អង្រួនម្ល៉ឹងហើយនៅតែមិនដឹងខ្លួន"?

ភីណាងាករឹងសម្លឹងត្រឡប់មកកាន់បន្ទប់ស្ត្រីបម្រើពីរនាក់ដែលនាងបានគោះទ្វារច្រើនដងហើយគ្មានការឆ្លើយតបដូចគ្នា។ ស្ថានភាពរបស់ពូសួសពេលនេះធ្វើឲ្យនាងកាត់យល់បានថា សូម្បីតែស្ត្រីចំណាស់ពីរនាក់នោះក៏ប្រហែលគ្មានស្មារតីដូចគ្នា។ នាងតូចដែលកាន់តែវិលវល់ក្នុងភាពរន្ធត់ ងើបមុខសម្លឹងសោឡានមួយជួរព្យួរលើដំណោកបុរស នេះ។ មួយប៉ប្រិចភ្នែកដំបូង គ្មានមួយណាដែលនាងអាចចំណាំបានថាសម្រាប់រថយន្តមួយណានោះទេ ប៉ុន្តែមានតែសោមួយដែលមានជាប់ជាមួយបន្តោងរូបត្រីនាគដែលនាងអាចចាំបានថាជាសោរថយន្តបងប្រុសធំនាង។ នាងស្ទុះទៅទាញវា ហើយរត់រឹងចេញទៅក្រៅផ្ទះ។ កណ្ដាលតំណក់ព្រះភិរុណដែលចេះតែបង្កើនអនុភាពខ្លាំងឡើងៗនោះ កល្យាណីភីណា បើកឡានចាកចេញពីភូមិគ្រឹះ

ដោយទឹកភ្នែកហូរសស្រាក់។ ដងផ្លូវស្ងាត់ច្រៀបគ្មានស្រមោលមនុស្សម្នាក់ហើយតំណក់ភ្លៀង ធ្លាក់បោកកញ្ចក់ពិទបាំងស្ទើរតែជិតឈឹងផ្នែកខាងមុខ។ នាងក្រមុំកាន់ចង្កូតដោយញ័រដៃទទ្រើកដោយសារនាងកម្របើករថយន្តខ្លួនឯង ពិសេសនេះជាប្រភេទរថយន្តទំនើបធំចង្រ្កាងផង នាងក៏កាន់តែឆ្លេឆ្លា។ ធីតាមានបំណងទៅដល់ផ្ទះម្ដាយមីងដែលរស់នៅមិនឆ្ងាយពីទីនេះប៉ុន្មាន ឲ្យបានឆាប់នឹងអាលរកគូដណ្ដឹងដែលមាននាទីជាប៉ូលិសស្រាប់ស្វែងរកជំនួយពីគេ។

អារម្មណ៍ច្របូកច្របល់កំពុងមានប្រសិទ្ធភាពលើរាងកាយស្រស់ស្រី ធ្វើឲ្យនាងបន្ថែមល្បឿនតាមសន្ទុះចិត្តអន្ទះសា។ រថយន្តបោលលឿនស្លេវទៅមុខ....គ្រាប់ភ្លៀងកាន់តែធ្លាក់ស្រោចព្រិលពិទបាំងកញ្ចក់ខាងមុខ...ក៏ស្រាប់តែលេចពន្លឺហ្វាពីទិសខាងស្ដាំ ធ្វើឲ្យស្រីស្អាតដែលគ្មានអារម្មណ៍នឹងន បង្ខំជាន់ហ្វ្រាំងពេញទំហឹង។ តែ...ដែលគ្មានផ្លូវរស់នោះគឺហ្វ្រាំងឡានបានដាច់ទៅហើយ! នាងបើកភ្នែកធំៗហើយបន្ទាប់មកស្រែកទ្រហោយំដោយទាល់ច្រកមុនពេលបត់ចង្កូតគេចចេញវឹង ធ្វើឲ្យរថយន្តបាត់ជំហររេទៅប៉ះគល់ដើមរុក្ខជាតិនៅលើចិញ្ចើមថ្នល់ម្ខាងលាន់គ្រាំបន្ទាប់មកក៏ឈប់ស្ងៀម។ នាងក្រមុំភីណាស្រស់សោភាសន្លប់ក្រាបក្បាលលើចង្កូតលែងដឹងខ្លួន។ ព្រះភិរុណស្រោចស្រពទៅលើឡាន និងម្ចាស់ស្រីដែលនៅស្ងៀមគ្មានកម្រើកកណ្ដាលស្បៃរាត្រីស្ងាត់សូន្យឈឹង។

## វគ្គទី២

## មនុស្ស ឬខ្មោច

ភីណាបើកភ្នែកព្រឹមៗ សម្លឹងពន្លឺថ្ងៃដែលចាំងចូលមកក្នុងបន្ទប់តាមប្រឡោះស្លាបព្រិល។ នាងកម្រើកខ្លួនប្រុងក្រោកអង្គុយ ប៉ុន្តែទទួលអារម្មណ៍ថាក្បាលឈឺខ្ទោកៗ ឯដងកាយទាំងមូលក៏ហាក់ដូចជាល្វិតល្វែអស់កម្លាំងណាស់។ នាងក្រមុំដៀងភ្នែកសម្លឹងជុំវិញខ្លួន ដូចជានឹកមិនឃើញថាទីនេះជាកន្លែងរបស់សាច់ញាតិម្នាក់សោះ។ នាងសម្លឹងទៅតុតូចក្បែរគ្រែដែលមានក្រូចពោធិ៍សាត់ខ្លះ និងផើងផ្កាស្រស់បំព្រង។ ឧបករណ៍ដាំទឹកក្ដៅប្រើដោយចរន្តអគ្គិសនីមួយ និងរបស់របរខ្លះទៀតនៅតែមិនអាចជួយឲ្យនាងចំណាំបានថាទីនេះជាកន្លែងណាសោះ។

នារីវ័យក្មេងច្រត់ដៃក្រោកអង្គុយផ្អែកខ្នងទៅនឹងក្បាលគ្រែ នាងលើកដៃជ្រោងសក់ប្រឹងរំលឹកទៅទាំងប៉ុន្មាន... នាងនឹកឃើញភ្លាមដល់រាត្រីពោរពេញទៅដោយភាពភ័យខ្លាចនោះ។ ហេតុការណ៍ទាំងប៉ុន្មាននាយប់នោះ បង្កឲ្យភីណានូវអារម្មណ៍ភ័យខ្លាចសាជាថ្មីមួយរំពេច នាងឈានជើងប្រុងក្រោកចុះពីលើគ្រែ ស្រាប់តែទ្វារបន្ទប់របើកលេចរូបបុរសម្នាក់ដើរចូលមកដល់។ គ្រាន់តែឃើញបុរសនោះភ្លាមភីណាបញ្ចេញក្តីត្រេកអរ ពោលហៅឈ្មោះគាត់ ដោយអាការរីករាយ៖

-បងកុសល!

បុរសក៏បង្ហាញក្តីរីករាយលើផ្ទៃមុខដែរ កាលបើឃើញនាងក្រមុំដឹងខ្លួនដោយប្រក្រតីយ៉ាងដូច្នេះ។ គាត់ស្ទុះចូលមកជិតប្អូនស្រី ទាំងពោលសួរ៖

-ដឹងខ្លួនហើយ ?

ភីណាញញឹមសួរវិញ៖

-នេះជាពេទ្យអ្វីបង?

-ត្រូវហើយ! អូនឯងសន្លប់ពីរថ្ងៃហើយ ឥឡូវនេះក្នុងខ្លួនយ៉ាងម៉េចហើយ?

នាងក្រមុំលើកដៃទាំងពីរជ្រោងសក់ទៅក្រោយទាំងអស់ ដោយពោលទៅកាន់បងប្រុសទាំងញញឹម៖

-អស់អីហើយ! អស់កម្លាំងបន្តិចទេតើ ...!

រំពេចនោះនាងនឹកភ្លែតដល់រឿងហេតុដែលកើតឡើងនាយប់មានភ្លៀងធំនោះ ហើយនាងក៏នឹកឃើញដល់ស្ថានភាពនារីជាបងថ្លៃដែលផុតដង្ហើមដេកស្តូកស្តឹងក្បែរជើងសាឡុង។ ភីណាបើកភ្នែកធំៗដោយអារម្មណ៍ភ័យខ្លាចចូលសណ្ឋិតក្នុងខ្លួនសាជាថ្មី ផ្ទៃមុខប្រែជាស្លេកស្លាំងហើយខ្លួនប្រាណញ័រចំប្រប់។ បុរសជាបងសម្លឹងឃើញប្រតិកម្មប្អូនស្រី គាត់ពោលសួរភ្លាមដោយភ្ញាក់ផ្អើល៖

-យ៉ាងម៉េច? ភីណា? អូនយ៉ាងម៉េចក្នុងខ្លួនហើយ?

នាងក្រមុំសម្លឹងមុខបងប្រុស...នាងទ្រហោយំហូរទឹកភ្នែកសស្រាក់។ យំបណ្តើរ ពោល អណ្តឺតអណ្តកបណ្តើរ៖

-បង...! អ្នកបង...គាត់...! គាត់...?

បុរសជាបងបង្ហាញអាការអស់សំណើច គាត់ពោលសួរដោយសម្លឹងប្អូនស្រីមិនដាក់ភ្នែក៖

-យ៉ាងម៉េចហ្នឹងភីណា? និយាយរកស្តាប់មិនបានសោះ យំធ្វើអ្វី?

ស្រស់ស្រីឈ្ងោកមុខយំខ្សឹកខ្សួល នាងពោលដោយរអាក់រអួល៖

-បងឯងត្រឡប់មកផ្ទះវិញអញ្ចឹងល្អហើយ...បើគ្មានបងខ្ញុំមិនដឹងត្រូវធ្វើម៉េចទេ!

លោកកុសលលូកដៃអង្អែលក្បាលប្អូនស្រីកំព្រាដោយក្តីស្រឡាញ់ និងអាណិត។ គាត់នឹកថា ប្រហែលជាបណ្តាលមកពីមួយរយៈដែលខ្លួនឃ្លាតឆ្ងាយពីនាង នាងឃ្លាតឆ្ងាយពីការយកចិត្តទុកដាក់ឈឺឆ្អាល អញ្ចឹងហើយទើបបណ្តាលឲ្យអារម្មណ៍ពោរពេញទៅដោយភាពសោកសៅយ៉ាងនេះ។ គាត់បន្តលួងលោមនាង៖

-អូនមិនដឹងទេអ្ហេះ! វិទូដឹងថាអូនគ្រោះថ្នាក់ភ្លាមគេមកមើលអូនរហូត អូនឯងដេកស្ងៀមពីរថ្ងៃមកនេះ គ្នាក៏គ្មានឈានជើងចេញទៅណាមួយជំហានដែរ ទើបតែអម្បាញ់មិញប៉ុស្តិ៍ប៉ូលិសមានការងារបន្ទាន់ទេ កុំអីអូនភ្ញាក់ឡើងក៏ឃើញរូបរាងស្លេកស្លាំងរបស់គេដែរហើយ។ នៅហ្នឹងសិនហើយ ...បងចេញទៅរៀបចំសំបុត្រសុំគេយកអូនឯងចេញទៅផ្ទះយើងវិញស្រួលជាង។ ពេទ្យថាឲ្យតែអូនឯងដឹងខ្លួន ទៅសម្រាកបំប៉នកម្លាំងមួយរយៈអស់អីហើយ...!

នាងក្រមុំងក់ក្បាល...ទឹកភ្នែកមិនទាន់ស្ងួតពីរង្វង់កែវភ្នែកនៅឡើយ នាងឆ្លើយតបនឹងសំដីបង៖

-អូនក៏ចង់ត្រឡប់ទៅផ្ទះឲ្យបានឆាប់ដែរ... !

បុរសជាបងក្រោកចេញពីប្អូន ល្មមពេលអ្នកកំលោះម្នាក់រុញទ្វារចូលមកក្នុងបន្ទប់...។ នោះគឺនាយប៉ូលិសវិទូដែលមិត្តអ្នកអាននៅចាំបានក្នុងសំណុំរឿងស្នូឪយោលេខ៧។ គេបញ្ចេញអាការភ្ញាក់ផ្អើល សម្លឹងមកភីណាដែលកំពុងអង្គុយផ្អែកខ្នងលើគ្រែ គេស្ទុះចូលមកជិតពោលដោយអំណរ៖

-ដឹងខ្លួនហើយ?

នាងក្រមុំមិនទាន់តបយ៉ាងណានៅឡើយ តែពាណិជ្ជករកុសលជាបងញញឹមឆ្លើយតបទៅកាន់អ្នកកំលោះ៖

-នាំគ្នានិយាយលេងទៅ បងចេញទៅធ្វើសំបុត្រសុំចេញពីពេទ្យឲ្យភីណា...!

ភីណាសម្លឹងដំណើរបងប្រុសដែលដើរប្រញាប់ប្រញាល់ចេញទៅ នាងងាកមកសួរអ្នកកំលោះដែលទាញកៅអីមកអង្គុយក្បែរគ្រែ៖

-បងកុសលថាបងត្រូវទៅធ្វើកិច្ចការបន្ទាន់នៅប៉ុស្តិ៍មែនអត់? ម៉េចក៏មិនទាន់ទៅទៀត?

អ្នកកំលោះញញឹមតបដោយសម្លឹងមុខនាង៖

-ដោះស្រាយរួចហើយ ក៏មកវិញភ្លាមហ្នឹង?

ភីណាញញឹម នាងប្រុងហើបមាត់និយាយតបទៅនឹងកំលោះជាគូដណ្ដឹង ក៏ស្រាប់តែទទួលអារម្មណ៍ថាឈឺក្បាលខ្ទោកៗ។ នាងជ្រួញចិញ្ចើមលើកដៃស្ទាបថ្ងាសដែលត្រូវបានរុំរបួសមិនទាន់ស្រាយចេញនៅឡើយ។ សម្លឹងឃើញប្រតិកម្មនាង អ្នកកំលោះបញ្ចេញភាពព្រួយបារម្ភលើផ្ទៃមុខមួយរំពេច។ គេប្រញាប់ប្រញាល់ពោលសួរស្រាលៗដោយយកចិត្តទុកដាក់៖

-យ៉ាងម៉េច? យ៉ាងម៉េចហើយ ?

ស្រីតូចពោលមិនឆ្លើយ នាងបែរជាសួរវិញទាំងជ្រួញចិញ្ចើមដោយក្ដីឈឺចាប់៖

-វិទូ ! ម៉េចក៏អូនឈឺត្រង់ក្បាលម្ល៉េះ...?

អ្នកកំលោះវិទូសម្លឹងមកនារីគូបញ្ជាំចិត្ត ដោយក្រសែភ្នែកព្រួយបារម្ភ។ គេពោលប្រាប់នាងស្រាលៗ៖

-កាលអូនរងគ្រោះក្បាលទង្គិចនឹងចង្កូតឡាន។ តែScanមើលអត់មានអីទាំងអស់! គ្រូពេទ្យថាឲ្យតែដឹងខ្លួនវិញសម្រាកបំប៉នខ្លួនមួយរយៈ លែងអីហើយ...!

ស្រស់ស្រីបញ្ចេញអាការក្រៀមក្រំលើផ្ទៃមុខ នាងវាចាបន្ត៖

-យប់នោះអូនបើកឡានទៅផ្ទះបងទេតើ! មិនស្មានថា...ក៏...!

វិទូពោលកាត់ភ្លាមៈ

-ភ្លៀងធំហើយយប់ជ្រៅទៀត ម៉េចក៏ហ៊ានបើកឡានតែម្នាក់ឯង?

នាងក្រមុំស្រមៃដល់ព្រឹត្តិការណ៍កាលពីយប់នោះ ហាក់លង់ក្នុងអារម្មណ៍ដូចនៅថ្មីៗ។ គ្រាន់តែមួយយប់សោះ គ្រួសារធ្លាប់សុខសាន្តក៏ប្រែក្លាយទៅជាមានរឿងអាសន្ន។ បងថ្លៃក៏ត្រូវស្លាប់យ៉ាងសោះកក្រោះ មិនដឹងថានៅក្នុងផ្ទះតាមពិតម្នាក់ៗកំពុងសោកសៅយ៉ាងណាទេ។ បងប្រុសខ្លួននៅទីនេះប្រឹងញញឹមនិយាយលួងលោមលើកទឹកចិត្តប្អូន ប៉ុន្តែគាត់ត្រូវបាត់បង់ប្រពន្ធជាទីស្រលាញ់ទៅហើយ មានរឿងអីថាមិនកើតទុក្ខនោះ?

រឹតតែគិត ក៏រឹតតែច្របូកច្របល់ក្នុងចិត្ត ក្បាលក៏កាន់ឈឺខ្លោកៗ...នាងក្រមុំជ្រួញចិញ្ចើមដោយពិបាកទ្រាំធ្វើឲ្យប៉ូលិសវិទូកាន់តែបង្ហាញក្តីបារម្ភជាងមុន គេពោលប្រាប់៖

-ភីណា! ឈប់គិតអីច្រើន! សម្ងំគេងសិនទៅ...មិនទាន់ស្រួលខ្លួនមែនទែនទេណា!

នាងក្រមុំធ្មេចភ្នែកទប់ស្កាត់ការឈឺចាប់ ប្រឹងសម្ងំសម្រាកតាមពាក្យអ្នកកំលោះពោលប្រាប់ដោយលែងចេញស្តីទៅរកនាយទៀត។ រសៀលដដែលនោះ នាងត្រូវបានបងប្រុស និងគូដណ្តឹងមកទទួលត្រឡប់ទៅផ្ទះ។ ក្នុងរថយន្តដែលកំពុងបោះពួយអាការបុរសទាំងទ្វេ រួមទាំងពូសួសអ្នកបើកឡានផង ក្រៅពីបារម្ភចំពោះនាងគឺដូចជាគ្មានកើតទុក្ខពីរឿងអ្វីទៀតសោះ ប្រការនេះបានធ្វើឲ្យនាងក្រមុំងឿងឆ្ងល់ចប់តាមផ្លូវ ប៉ុន្តែនាងនៅសម្ងំស្ងៀមចាំឲ្យទៅដល់ផ្ទះវិញសិនចាំសួរនាំ។

មកដល់មាត់ទ្វាររបង រថយន្តលូនចូលសន្សឹមៗទៅក្នុងបរិវេណភូមិគ្រឹះ ដោយមានអ្នកបម្រើចំណាស់រត់មកទទួលរង់ចាំបម្រើដូចសព្វដង ប៉ុន្តែភីណាងឿងឆ្ងល់ត្រង់ថាគេហដ្ឋានរបស់ខ្លួនមានមនុស្សស្លាប់ គឺជាក្តីសោកសៅខ្លាំង សម្បើមណាស់ ចុះហេតុអ្វីបែរជាមិនឃើញមានរៀបចំពិធីបុណ្យសព ឬក៏មានសញ្ញាកាន់ទុក្ខអ្វីសោះយ៉ាងនេះ...។

...បងថ្លៃស្រីរបស់ខ្លួនស្លាប់ក្នុងផ្ទះ គួរណាស់មានរៀបចំពិធីបុណ្យតាមប្រពៃណី ប៉ុន្តែជើងឈានដល់បន្ទប់ទទួលភ្ញៀវទៅហើយ បរិយាកាសក្នុងផ្ទះនៅតែរក្សាបាននូវភាពប្រក្រតី ក្រៅពីមានអ្នកបម្រើប្រុសស្រីស្ទុះមកជួយគ្រានាង គឺគ្មានឃើញអ្វីទៀតសោះ។ នាងចងចិញ្ចើម

ដោយក្ដីងឿងឆ្ងល់ រវេក្នែកសម្លឹងពេញផ្ទៃបន្ទប់ទទួលភ្ញៀវ រួចទើបពោលទៅកាន់ស្ត្រីចំណាស់ដែលកំពុងគ្រានាងឲ្យដើរ៖

-មីងម៉ាប់! លែងខ្ញុំទៅ ខ្ញុំដើរខ្លួនឯងបានហើយ!

ស្ត្រីឈ្មោះម៉ាប់ពោលតបវិញដោយអាការអល់អែក៖

-នាងតូច! នាងមិនទាន់ជាស្រួលបួលទេ...ទុកឲ្យខ្ញុំគ្រាឡើងលើទៅ!

ភីណាតបវិញដោយមួហ្មងតាមទម្លាប់ដែលមិនចង់ឲ្យអ្នកផងមើលមកថាខ្លួននាងទន់ខ្សោយ៖

-ខ្ញុំមានឈឺជើងឯណាមីង? ខ្ញុំដើរខ្លួនឯងបាន...!

អ្នកបម្រើមិនហ៊ានប្រកែកនឹងបង្គាប់ គាត់លែងដៃពីនាងក្រមុំទាំងរារែក...។ តែលោកកុសលពោលប្រាប់ប្អូនពីចម្ងាយ៖

-ភីណា! ឲ្យមីងម៉ាប់គ្រាឡើងទៅ យើងមិនទាន់ជាស្រួលបួលទេ!

ភីណាមិនទាន់បានតបវិញយ៉ាងណាផង ក៏ស្រាប់តែលាន់ឮសំឡេងស្រួយស្រើបមកពីជាន់ខាងលើ៖

-មិនអីទេមីងម៉ាប់! ភីណាជាមនុស្សមាំទាំតាំងពីដើមមក!

សព្ទសំឡេងមួយឃ្លានេះបញ្ឆាក់ចិត្តនាងក្រមុំភីណាឲ្យភ្ញាក់ស្ទើរផ្ងារក្រោយ ដោយងើបមុខសម្លឹងទៅខាងលើប្រភពនៃសូរសំឡេងភ្លាម...ពេលក្រសែភ្នែកវាត់ទៅប៉ះនឹងរូបរាងមនុស្សម្នាក់ដែលកំពុងញញឹមស្រស់បោះជំហានមួយៗ ចុះមកពីជណ្ដើរ ហើយម្នាក់នោះឯងដែលភីណាឃើញមុខកាលណាភ័យស្ទើរលោះព្រលឹង ...ព្រោះថាម្នាក់នោះ គឺបងថ្លៃស្រីរបស់នាងទាំងសាច់ទាំងឈាម។

ក្រមុំអ្នកជំងឺបើកភ្នែកគ្រលួងសម្លឹងអ្នកស្រីកុលាប ដែលកំពុងឈានយឺតៗចុះមកស្រាលស្ញើកពីលើជណ្ដើរបង្អួតពីមុខភាពស្រទន់ឡាំងកាំងរបស់ខ្លួន។ដោយភាន់ភាំងក្នុងចិត្ត រឿងហេតុកាលពីយប់នោះលេចធ្លោឡើងក្នុងកែវភ្នែកភីណាដូចនៅថ្មីៗ។ នាងនៅចាំថាបងថ្លៃស្រីរូបនេះបានដួលរមៀលពីលើជណ្ដើររហូតដល់ក្រោម ហើយបោកទង្គិចនឹងជើងសាឡុងពេញមួយទំហឹង។

យប់នោះគាត់មិនត្រឹមហូរឈាមតាមច្រមុះ និងមាត់ទេ សូម្បីតែដង្ហើមក៏លែងដកហើយដែរ។

ប៉ុន្តែសម្លឹងដល់អ្នកណា...ក៏ឃើញតែគេមើលត្រឡប់មកនាងវិញដោយក្រសែភ្នែកងឿងឆ្ងល់។ ភីណាជ្រួញចិញ្ចើមដោយវិលវល់ក្នុងចិត្ត នាងពោលៈ

-ទាំងអស់គ្នាសម្លឹងមកខ្ញុំអីរបៀបនេះ? ម៉េចក៏មើលមកខ្ញុំដូចជាចម្លែកម្ល៉េះ?

លោកកុសលបន្លឺឡើងមុនគេៈ

-កើតអីភីណា? និយាយស្ដីស្អីជាមួយអ្នកបងឯងរបៀបនេះ?

ភីណាងាករឹងមករកបងប្រុសទាំងមិនអស់ចិត្ត ។

ឬមួយក៏ពួកគេសុទ្ធតែមិនដឹងថាបងថ្លៃរូបនេះបានធ្លាក់ពីលើជណ្ដើរស្លាប់កាលពីយប់នោះទៅហើយទេ?

នាងនៅទីទើរមិនដឹងគួរហាមាត់និយាយយ៉ាងណាឲ្យសមសោះ ស្រាប់តែឮបងថ្លៃវ័យក្មេងនោះលូកមាត់ពោលកាត់ភ្លាមៈ

-បន្ទោសភីណាធ្វើអីបង! ប្អូនទើបនឹងចេញពីពេទ្យស្មារតីមិននឹងនអញ្ចឹងហើយ ...!

គាត់ងាកមករកភីណា ដោយស្នាមញញឹមស្រស់នៅជិតដាមលើបបូរមាត់ជាប់នៅឡើយ ។

-តោះ! បងជូនឡើងទៅសម្រាកខាងលើ!

អ្នកស្រីកុលាបលូកដៃទៅរករាងកាយស្រីតូចភីណា តែត្រូវនាងក្រមុំរលាស់ចេញដោយអាការភិតភ័យ...នាងពោលញ័រមាត់ទទ្រើកដោយសម្លឹងអ្នកស្រីវ័យក្មេងមិនដកភ្នែកៈ

-កុំចូលមកជិតខ្ញុំ...! កុំប៉ះខ្ញុំឲ្យសោះ! ចេញទៅ! ចេញឲ្យឆ្ងាយទៅ...!

អ្នកស្រីកុលាបនៅស្ងៀមលែងចូលក្បែរភីណា ហើយធ្វើភ្នែកឡិងឡង់ហាក់មិនយល់។ អភិជនមានអំណាចជាងគេនៅទីនេះសម្លឹងមកកាន់ប្អូនស្រី របៀបមិនស្រួលចិត្ត។ នៅក្នុងអារម្មណ៍គាត់មានតែសំណួរមួយប៉ុណ្ណោះ គឺថាតើគ្រោះថ្នាក់ចរាចរណ៍នោះធ្វើឲ្យប៉ះពាល់ដល់ផ្លូវចិត្តក៏ប្រព័ន្ធសរសៃប្រសាទរបស់នាង?

រិទូយល់ថាបរិយាកាសនៅសុខៗស្រាប់តែប្រែទៅជាតឹងតែងហាក់គ្មានទំនងដែរ ម៉្លោះហើយអ្នកប្រឹងសម្រួលបរិយាកាសដោយពោលប្រាប់ទៅអ្នកបម្រើ៖

-មីងអួនមីងម៉ាប់! ភីណាត្រូវការសម្រាកឲ្យច្រើន មីងជូនគេទៅខាងលើទៅ...!

ទោះជាអ្នកកំលោះគួរដណ្ដឹង ប្រឹងស្ដារបរិយាកាសយ៉ាងណាក៏ភីណាមិនបោះបង់ចោលការតក់ក្រហល់របស់ខ្លួនដែរ។ នាងងាកមករកបងប្រុសតក្កមា៖

-បងកុសល! អ្នកបង....អ្នកបង....

នាងបញ្ឈប់ប្រយោគកណ្ដាលទី ទោះបីជានាងកំពុងចង់បង្ហើយថាអ្នកបងនាងបានស្លាប់ទៅហើយក៏ដោយ ក៏នាងនិយាយមិនចេញអស់ដែរដោយសារភាពរន្ធត់ស្រុតស្រុំរាងកាយ។

នាងលើកដៃចង្អុលទៅស្ត្រីរូបស្អាតសាជាថ្មី ហើយប្រឹងនិយាយបន្ថែម៖

-អ្នកបងស្លាប់ហើយ! នេះមិនមែនអ្នកបងទេ! មិនមែនគាត់ទេ!

គ្រប់គ្នាស្ងាត់ច្រៀប នៅពេលដែលស្ត្រីដែលត្រូវបានគេចោទថាស្លាប់ ចាប់ប្រែប្រួលទឹកមុខទៅជារន្ធត់វិញម្ដង។ អាការរបស់នារីជាភរិយាលោកកុសលបញ្ចេញមកថា សម្ដីចុងក្រោយរបស់ប្អូនថ្លៃដែលពោលប្រមាថជីវិតនាង មិន អាចឲ្យនាងទទួលយកបានឡើយ។ លោកកុសលដំឡើងសំឡេង៖

-ភីណា!? ឆ្កួតអត់ទេនេះ?

ភីណាសម្លឹងមុខបងប្រុសថ្លៃ នាងដៀងភ្នែកមើលអ្នកទាំងអស់ដែលនៅជុំវិញខ្លួនដែលគ្មានសញ្ញាថាមានអ្នកណាម្នាក់បានយល់ពីអ្វីដែលនាងកំពុងព្យាយាមប្រាប់សោះ។ នាងនៅតែជម្ទះឧទានដោយមិនអស់ចិត្ត៖

-ទាំងអស់គ្នាដឹងអត់? អ្នកបងស្លាប់ហើយ...អ្នកបងស្លាប់មែន!

នាងបញ្ចប់ឃ្លានេះជាមួយការស្រែកទ្រហោយំ។

នាយប៉ូលិសរិទូមិងមាំង ពេលឃើញស្រីស្អាតខ្ទប់មុខយំដូចក្មេង។ គេរវេភ្នែកសម្លឹងលោកកុសលជាមួយការគិតប្រហែលគ្នាថារបួសរបស់នាងប្រហែលជាដើមហេតុនៃអាកប្បកិរិយាថ្មី

ហាក់ដូចជាមនុស្សមិនដឹងខុសត្រូវនេះ។ខណៈដែលមនុស្សទាំងអស់ដូចជាគ្មានអ្នកណាម្នាក់យល់ស្របលើសម្ដីខ្លួនសោះនោះ...ភីណានិយាយបន្ថែមដោយអណ្ដឺតអណ្ដក៖

-អ្នកបងដាច់ដង្ហើមហើយ! គាត់ហូរឈាមតាមមាត់ និងតាមច្រមុះ...គាត់...

ប្រហែលសម្ដីចុងក្រោយនេះវាហួសពីព្រំដែនកំណត់សម្រាប់ដើមទ្រូងបុរសជាស្វាមីម្នាក់អាចទទួលយកបាន បានជាលោកកុសលគំហកកាត់ដោយសូរសំឡេងឮៗ៖

-នាំភីណា ឡើងទៅលើសម្រាកទៅ...!

អ្នកបម្រើទាំងទ្វេឆ្លើយចាំះ ដោយភ័យស្លន់ជាមួយប្រតិកម្មកំហឹងរបស់បុរសមេគ្រួសារ ហើយស្ទុះចូលមកក្បែរនាងក្រមុំហាក់ញញើតញញើមខ្លាចចិត្ត។...មីងអួនពោលតិចៗក្បែរសោតាក្រមុំយើង៖

-នាងតូច!...តោះឡើងទៅខាងលើសម្រាកសិន...!

ភីណាមិនខ្វល់នឹងអ្នកបម្រើ នាងនៅតែផ្ដោតសម្លឹងស្ត្រីដែលស្អាតបំផុតនៅផ្ទះនេះ...នាងសម្លឹងមុខគាត់ ហាក់ចង់មើលឲ្យធ្លុះថាគាត់ជាអ្នកណា...ម៉េចក៏មកក្លែងបន្លំធ្វើជាបងថ្លៃរបស់នាង...? ភាពមិនអស់ចិត្តកាន់តែដុតកម្ដៅទ្រូងនាងក្រមុំខ្លាំងឡើងៗ នាងស្រែកៗខ្លាំងៗដោយកំហឹង៖

-ម៉េចក៏គ្មានអ្នកណាស្ដាប់សម្ដីខ្ញុំ... មានមនុស្សស្លាប់ហើយអាចរស់ឡើងវិញដែរអ្ហេស៎?

អ្នកស្រីកុលាបដូចជាគ្មានបញ្ចេញប្រតិកម្មអវិជ្ជមានណាមួយតបមករកភីណាបន្តិចសោះ...គាត់ដើរចូលមកជិតនាងហើយពោលស្រាលៗ៖

-ភីណា! តោះបងជូនឯងទៅខាងលើសម្រាក!

ក្នុងពេលអ្នកផងយល់ថាអ្នកស្រីកុលាបមិនប្រកាន់ជាមួយភីណានោះ នៅខាងណោះវិញ នារីជាប្អូនបែរជាយល់ថា ស្ថានការណ៍កាន់តែមិនប្រក្រតីហើយរឿងចម្លែកនេះ កំពុងតែកកូរឲ្យវឹកវរគ្រួសាររបស់នាងប្រាកដណាស់។ ភីណាស្រវាដកថយចេញឆ្ងាយពីស្ត្រីជាបងថ្លៃដោយរំជួលចិត្ត...នាងបន្លឺខ្លាំងៗរបៀបខឹងសម្បារ៖

-ចង់ធ្វើស្អី? អ្នកឯងមកពីណា...ហេតុអ្វីចង់បន្លំជាអ្នកបង? អ្នកឯងចង់បានស្អី?

លោកកុសលស្ទុះមកក្បែរប្អូនស្រី គាត់ទាញដៃនាងសំដៅជណ្តើរទាំងកំហឹងអមចេញមកតាមរយៈសូរសំឡេងគគ្រឹតធ្មេញ៖

-តោះឡើងលើ!

នាងក្រមុំដែលត្រូវចាប់ដៃជាប់ងាកមកសម្លឹងមុខបងប្រុសថ្មៃ... នាងមិនអស់ចិត្ត នាងខឹងណាស់ ហេតុអ្វីសម្តីខ្លួនគ្មានអ្នកណាស្តាប់សោះ? សូម្បីសួរនាំបន្តិចក៏អត់? នាងហៀបនឹងនិយាយតបតតាមកំហឹងចិត្តទៅហើយ... តែវិទូដែលយល់ស្ថានការណ៍ ស្ទុះមកក្បែរពោលសម្រួលបរិយាកាស៖

-ភីណា!... ចង់និយាយអីក៏ដោយ!... ចាំសម្រាកបានស្រួលបួលសិនទៅ...!

នាងងាកមករកបុរសគូរដណ្តឹង ក្រសែភ្នែកនាងនៅតែទទូចចង់ប្រាប់នាយពីរឿងអ្វីមួយ តែប៉ូលិសវិទូនិយាយកាត់បន្ថែមភ្លាម៖

-ស្តាប់បង... ឡើងទៅលើសិនទៅ...ណ៎ា! អូខេ? សម្រាកឲ្យបានជាស្រួលបួលសិនណ៎ា!

នាងក្រមុំមិនបានរសាយចិត្តពីភាពមួហ្មងបន្តិចណាទាល់តែសោះទេ...ប៉ុន្តែក្នុងពេលនេះក្បាលបែរជាឈឺខ្ទោកៗដោយមុខរបួសមិនទាន់បានសះស្បើយ១០០%នៅឡើយ។ នាងសម្រួលដង្ហើមយូរហើយងាកមករកអ្នកបម្រើដែលប្រកបដោយអាការញញើតញញើមឈរក្បែរនោះ។ ស្រីតូចពោលរអាក់រអួល៖

-មីងអួន!...ជូនខ្ញុំឡើងទៅបន្ទប់...!

អ្នកបម្រើចំណាស់រូបនោះ ស្ទុះមកគ្រានាងក្រមុំតាមបង្គាប់សំដៅទៅជាន់ខាងលើ។ ភីណាដើរមួយៗទាំងឈឺក្បាលខ្ទោកៗ ណាចិត្តក៏មិនស្រណុកផង នាងកាន់តែយល់ថាពិបាកទ្រាំណាស់ តែនាងខំអត់ធ្មត់ដោយសាររាងកាយកាន់តែខ្សោយជាលំដាប់។

ក្រមុំអភិជនឈានដល់កម្រាលឥដ្ឋជាន់ខាងលើភ្លាម ក៏ងៀងភ្នែកសម្លឹងទៅរកបន្ទប់វត្ថុបុរាណភ្លាមដែរ។ ថូផ្កាពណ៌សដែលតាំងលើតុខ្ពស់មុខបន្ទប់ ពេលនេះពិតជាបាត់លែងឃើញហើយ។ ភីណាកាន់តែជឿជាក់យ៉ាងច្បាស់ ក្នុងចិត្តថា រឿងហេតុកាលពីយប់ដែលមានភ្លៀងធ្លាក់នោះ ខ្លួននៅចាំច្បាស់គ្មានច្រឡំឡើយ បងស្រីថ្លៃរបស់ខ្លួន កាលយប់នោះបានចាប់លើកថូមកការពារខ្លួនមុននឹងចូលទៅក្នុងបន្ទប់វត្ថុបុរាណ ប៉ុន្តែពេលក្រឡេកឃើញមនុស្សប្រុសពីរ

នាក់ គាត់ភ័យរបូតដៃធ្វើឲ្យថូធ្លាក់បែកខ្ចាយទៅលើកម្រាលឥដ្ឋ ឥឡូវនេះថូនោះបាត់ គឺជាការត្រឹមត្រូវណាស់ ប៉ុន្តែបងថ្លៃខ្លួនដែលបានដាច់ដង្ហើមទៅហើយ ហេតុអ្វីថ្ងៃនេះគាត់បែរជានៅហាក់ធម្មតាទៅវិញ? ហេតុការណ៍ចម្លែកទាំងនេះតើឲ្យទទួលយកម៉េចនឹងបាន?

តរុណីឈានយឺតៗចូលមកដល់បន្ទប់ផ្ទាល់ខ្លួនដែលស្ងប់ស្ងាត់ដូចអារម្មណ៍ក្រៀមស្រពោនរបស់ម្ចាស់វាដូច្នេះដែរ។ ក្នុងភាពអាប់អួមិនជ្រះស្រឡះចិត្តសោះ នាងមិនអាចទប់ទៀតបានទើបងាកមកអ្នកបម្រើចំណាស់ដែលចច្រប់បើកទូររីករកសម្ភារៈនានាមកបម្រើខ្លួននៅក្បែរ។ នាងសួរគាត់តិចៗ៖

-មីងអួន...! យប់នោះមីងកើតអី? មីងនៅក្នុងបន្ទប់ជាមួយមីងម៉ាប់មែនអត់? ម៉េចក៏ពេលមានរឿងខ្ញុំស្រែកផង ហៅផងមីងនៅតែមិនឆ្លើយ?

អ្នកបម្រើរូបនោះបើកភ្នែកគ្រលួងបង្ហាញសញ្ញាងឿងឆ្ងល់។ គាត់មិនទាន់តបថាយ៉ាងណាផងស្រីតូចនិយាយជាថ្មី៖

-ខ្ញុំនិយាយពីយប់ដែលខ្ញុំមានគ្រោះថ្នាក់នោះ!

អ្នកបម្រើពោលមួយៗទាំងបើកភ្នែកគ្រលួងផង៖

-យប់នោះខ្ញុំពិតជាគេងលក់ជាមួយម៉ាប់មែន! តែនៅម៉ោងជិតមួយយប់ មានទូរសព្ទពីមន្ទីរពេទ្យមកថានាងតូចត្រូវបញ្ជូនចូលមន្ទីរពេទ្យហើយ!

ភីណាបើកភ្នែកធំៗ នាងពោលសួរកាត់ភ្លាម៖

-មីងថាម៉េច? ទូរសព្ទអ្ហេះ? ទូរសព្ទនោះក្រែងដាច់ខ្សែបាត់ហើយអ្ហេះ? យប់នោះខ្ញុំចុចទូរសព្ទទៅរកបងទូ ប៉ុន្តែទូរសព្ទដាច់ប្រើមានកើតឯណា មីងថាគេទូរសព្ទពីមន្ទីរពេទ្យមក តើមានន័យថាម៉េច?

ស្ត្រីរូបនោះទៅជាទីទើរកាលបើបានស្តាប់ឮសម្តីនាងក្រមុំ គាត់ពោលតប៖

-ទូរ...ទូរសព្ទនោះ មានខូចឯណា? នាងតូចច្រឡំទេដឹង? ពេលខ្ញុំរត់មកដល់ ទូរសព្ទនៅធម្មតាតើ!

ភីណារឹតតែភ្ញាក់ផ្អើលក្នុងចិត្ត នាងនៅចាំយ៉ាងច្បាស់ថាយប់នោះ ពេលឃើញបងថ្លៃស្រីត្រូវធ្លាក់ស្លាប់ ខ្លួនភ័យស្លន់ស្លោណាស់ ក៏ស្រវាទូរសព្ទដើម្បីចុចទៅប្រាប់វិទូ ប៉ុន្តែទូរសព្ទក៏ដាច់ប្រើមិនកើតទៀត ទើបខ្លួនសម្រេចចិត្តបើកឡានចេញពីផ្ទះដោយតក្កមាធ្វើឲ្យជួបគ្រោះថ្នាក់តែម្តង ចុះម្តេចក៏ពេលវិលត្រឡប់មកដល់ផ្ទះវិញ អ្វីៗក្លាយជាយ៉ាងនេះ?

នាងខ្វល់ខ្វាយជាខ្លាំងចំពោះមុខរឿងហេតុមិនប្រក្រតីទាំងអស់ តែនាងក៏ដឹងដែរថា បើនាងនៅតែមានះបកស្រាយរឿងរ៉ាវនេះដោយតឹងតែងពេក អ្នកបម្រើនឹងភ័យស្លុតតាមដែរមិនខាន ដូច្នេះទើបនាងប្រញាប់ទម្លាក់សំឡេងសួរទៅកាន់អ្នកបម្រើសាជាថ្មី៖

-ចុះពេលហ្នឹងមីងមកដល់ផ្ទះធំឃើញ...ឃើញ...អ្វីខ្លះ? មីងមាន...មាន....មានឃើញអ្នកបងទេ?

អ្នកអួនតបវិញ គ្មានអាការត្រង់ណាបញ្ជាក់ថាគាត់ធ្វើពើ ឬនិយាយកុហកវៀចវេរទេ៖

យប់នោះខ្ញុំឮសូរទូរសព្ទក៏រត់មក! ចំណែកម៉ាប់ក្រោកមកតាមក្រោយ! ពេលហ្នឹងខ្ញុំងើបមើលនាឡិកាឃើញថាម៉ោងជិតមួយយប់ហើយ នឹកថាមានរឿងអីបានជាមានគេខលមកកណ្តាលអធ្រាត្រ ក៏រលះរលាំងរត់មក... មេឃភ្លៀងទើបនឹងរាំងមិនទាន់ដាច់គ្រាប់ ....

ស្រីតូចកាន់តែតឹងចិត្ត នាងមិនអាចអត់ធ្មត់បានក៏និយាយកាត់៖

-ឈប់និយាយរឿងអត់សាច់ការទៅមីង! ខ្ញុំចង់ដឹងថាមីងមកដល់ភ្លាម ឃើញអីខ្លះនៅផ្ទះធំ?

អ្វីដែលភីណានាងចង់ដឹងបំផុត គឺសាកសពបងថ្លៃដែលរមៀលធ្លាក់មកពីខាងលើនោះហើយ ប៉ុន្តែស្ត្រីបម្រើនោះបែរជាបញ្ចេញភាពងឿងឆ្ងល់តាមរយៈពន្លឺភ្នែក មុនពេលនិយាយត្រួសៗរៀបរាប់ពីទិដ្ឋភាពកាលពីយប់នោះ។

-ផ្ទះធំធម្មតាគ្មានអ្វីប្លែកផង! ខ្ញុំនឹកថាអ្នកស្រី និងនាងតូចនៅសម្រាន្តខាងលើ តែដល់ពេលមន្ទីរពេទ្យទូរសព្ទមកប្រាប់ថាអ្នកនាងតូចមានគ្រោះថ្នាក់ ទើបខ្ញុំដឹងថានាងតូចអត់នៅផ្ទះទេ! ខ្ញុំស្លន់ឲ្យម៉ាប់ទៅតាមពូសួស ហើយខ្ញុំរត់ឡើងទៅខាងលើជម្រាបអ្នកស្រី!

ភីណាបើកភ្នែកធំៗ នាងពោលសួរសង្ស័យ៖

-មីងថាមីងឡើងទៅជម្រាបអ្នកបងខាងលើអ្ហេស? មីងឡើងទៅដល់ឃើញគាត់កំពុងធ្វើអ្វី?

មីងអួនឆ្លើយតបវិញភ្លាម៖

-អ្នកស្រីកំពុងសម្រាន្តដូចធម្មតា!

ភីណាវិលវល់ ....នាងនឹកគិតយ៉ាងណាក៏គិតមិនយល់សោះ។ យប់នោះនាងឃើញបងថ្លៃខ្លួនដាច់ដង្ហើមស្លាប់ដោយផ្ទាល់នឹងភ្នែក ចុះម៉េចក៏នៅម៉ោងមួយក្រោយមកមីងអួនថាឃើញបងថ្លៃខ្លួនកំពុងសម្រាន្តក្នុងបន្ទប់ដូចធម្មតាទៅវិញ?

ស្រីតូចងាកមករកអ្នកបម្រើចំណាស់ សម្លឹងផ្ទៃមុខរបស់គាត់ គឺមិនសមថាគាត់និយាយកុហកទេ។ នាងលើកដៃជ្រោងសក់ដោយខ្វល់ខ្វាយ។ អ្នកអួនបញ្ចេញទឹកមុខអាណិតអាសូរមកកាន់នាង ទើបគាត់និយាយលួងលោម៖

-នាងតូចសម្រាកទៅ! ខ្ញុំចុះដួសបបរមកជូន!

ភីណាគ្រវីក្បាលយឺតៗបន្ទាប់ពីអារម្មណ៍ភាន់ភាំង។ រំពេចនោះនាងស្រាប់តែនឹកដល់រឿងថូផ្កាពណ៌សនោះ នាងពោលសួរមួយរំពេច៖

-មីងអួ៎ា! ចុះថូផ្កាដែលតាំងមុខបន្ទប់វត្ថុបុរាណនោះទៅណាបាត់ហើយ?

អ្នកអួនតបដោយសម្លឹងមុខនាងក្រមុំគ្មានព្រិច៖

-ឆ្មារំលំថូនោះបែកហើយ...! ពេលខ្ញុំរត់ឡើងមកដល់លើ ឃើញខ្ទាយពេញដី!

ស្រីតូចងឺងើ នាងសើចខឹកចំអកខ្លួនឯងរួចសួរដោយហួសចិត្ត៖

-អញ្ចឹង? ហើយចុះពីណានិយាយប្រាប់មីង?

ស្ត្រីនោះតបមួយៗ៖

-គឺ..គឺ.អ្នកស្រី!

ភីណាហួសចិត្ត នាងពោលសួរអ្នកបម្រើវិញ៖

-មីងអួន គាត់ថាអញ្ចឹង មីងក៏ជឿដែរអ្ហេស៎? ផ្ទះយើងមានសត្វឆ្មាពីណាមក? ថូនោះអ្នកបងកុលាបគាត់របូតដៃជ្រុះបែកខ្លួនឯងទេ! យប់នោះគាត់នៅជាមួយខ្ញុំ ខ្ញុំឃើញផ្ទាល់ភ្នែក!

អ្នកបម្រើរូបនោះសម្លឹងមកភីណាដោយក្រសែភ្នែកមិនជឿជាក់។ ទោះយ៉ាងណា ទម្លាប់មិនស៊ីសង្វាក់គ្នារវាងបងប្អូនថ្លៃស្រីទាំងពីរ អ្នកណាក៏ដឹងដែរក្នុងផ្ទះនេះ ប៉ុន្តែរហូតដល់ថ្ងៃនេះភីណានិយាយថាបងថ្លៃខ្លួននិយាយកុហកពីរឿងចូគ្មានទំនងត្រង់ណាគួរឲ្យជឿសោះ ព្រោះថាមានហេតុផលអ្វីដែលអ្នកស្រីកុលាបចាំបាច់ប្រឌិតរឿង?

ទោះជាចូនោះថ្លៃយ៉ាងណាក៏គាត់ជាម្ចាស់ស្រីធំរបស់ផ្ទះនេះស្រាប់ទៅហើយគ្មានរឿងអ្វីថាមិនហ៊ានសារភាពខ្លួនធ្វើបែកទេ។ ឃើញ-មីងនោះនៅទីទើរក្នុងការហើបមាត់តបតសម្ដីខ្លួន នាងក្រមុំជ្រួញចិញ្ចើមពោលសួររឹង៖

-មីងយ៉ាងម៉េចហ្នឹង? មិនជឿខ្ញុំទេអ្ហេស៎? ម៉េចក៏ខ្ញុំនិយាយប្រាប់ការពិតគ្មានអ្នកណា ជឿខ្ញុំសោះ...! មីងដឹងទេ យប់នោះពេលមីងចេញផុត ផ្ទះយើងមានចោរលួចចូលមកទៀតផង!

**ភាគទី៤**

មីងអួនបើកភ្នែកធំៗ គាត់សួរវិញយ៉ាងរហ័ស៖

-តែ...ម៉េចក៏មិនឮអ្នកស្រីនិយាយប្រាប់ខ្ញុំ?

ភីណាចងចិញ្ចើមដោយមិនសប្បាយចិត្ត នាងពោលសួរបន្ត៖

-អញ្ចឹងមីងមានឆ្ងល់ទេ ម៉េចបានខ្ញុំបើកឡានចេញពីផ្ទះទាំងយប់?

អ្នកបម្រើចំណាស់តបដោយអាការអល់អែក៖

-តែអ្នកស្រីថា....(គាត់ទីទើរហើយបញ្ឈប់សម្ដី)

តែភីណាសួរបន្តភ្លាម៖

-អ្នកបងយ៉ាងម៉េច? គាត់ប្រាប់មីងថាម៉េច?

ស្ត្រីចំណាស់ឆ្លើយតបតាមត្រង់៖

-អ្នក....អ្នកស្រីថាយប់នោះនាងតូចមិនចង់គេងផ្ទះ ចចេសចង់ទៅផ្ទះមិត្តភ័ក្តិ! អ្នកស្រីឃាត់យ៉ាងណាក៏មិនស្ដាប់ ទើបអ្នកនាងតូចបើកឡានទៅទាំងភ្លៀងរហូតដល់កើតគ្រោះថ្នាក់!

ស្រស់ស្រីសែនមួហ្មងក្នុងចិត្ត នាងដឹងថា...គឺបងថ្លៃស្រីមានចេតនានិយាយបំផ្លើសគ្រាន់តែមិនដឹងថាគេមានបំណងអ្វីឲ្យប្រាកដប៉ុណ្ណោះ។

ក្ដីងឿងឆ្ងល់កាន់តែរុកគួនក្នុងចិត្តតរុណើភីណាខ្លាំងជាងមុនទៅទៀត...។ សំខាន់នាងគិតមិនយល់ថា នាងមិនដឹងថាម៉េចក៏បងថ្លៃរបស់ខ្លួនដែលបានធ្លាក់ពីលើជណ្ដើរស្លាប់បាត់ទៅហើយនោះ បែរជារស់ឡើងវិញហើយនិយាយប្រាប់គេឯងផ្ទុយពីការពិតយ៉ាងនេះ?

កំពុងស្ថិតក្នុងអារម្មណ៍ស្មុគស្មាញ...នាងឮអ្នកបម្រើចំណាស់ពោលៈ

-នាងតូចសម្ងំសម្រាកឲ្យបានស្រួលទៅ! ខ្ញុំចុះទៅរៀបចំបបរជូនក្រែងអ្នកនាងដល់ពេលពិសាថ្នាំសិន!

ភីណាងក់ក្បាលយឺតៗដោយមិនចេញស្ដី នាងសម្ងំបិទភ្នែករំលែកអារម្មណ៍ស្មុគស្មាញទាំងប៉ុន្មានឲ្យបានធូរស្បើយខ្លះ ប៉ុន្តែរឿងហេតុទាំងប៉ុន្មាន បែរជាសណ្ឋិតជាប់ក្នុងអារម្មណ៍ដកមិនរួចទៅវិញ។

នាងនឹកដល់ពេលដែលនាង និងបងថ្លៃអង្គុយនៅបន្ទប់ទទួលភ្ញៀវ យប់នោះភ្លៀងខ្លាំងសម្បើមណាស់ ប៉ុន្តែទាំងពីរនាក់សុទ្ធតែបានឮដូចៗគ្នាថាមានសម្រិបជើងមនុស្សរត់ជាន់ខាងលើ កាលណោះនាង និងបងថ្លៃឡើងទៅមើលដោយភិតភ័យ បន្ទាប់មកក៏នាំគ្នារត់ចុះមកខាងក្រោមវិញ ប៉ុន្តែដោយបងថ្លៃស្លៀករ៉ូបរាត្រីវែងពេកក៏ទាក់ជើងដួលរមៀលតាមជណ្ដើររហូតដល់ហូរឈាមតាមច្រមុះមាត់។ ចុងក្រោយនាងបានទាំងស្ទាបដង្ហើមគាត់ ដឹងថាគាត់ផុតដង្ហើមស្លាប់ពិតណាស់! ចុះម៉េចក៏ពេលនេះ បែរជា...?

ភីណាគ្រវីក្បាលបដិសេធមិនទទួលស្គាល់ថាបងថ្លៃរបស់ខ្លួននៅមានជីវិតទេ។ នាងមានការជឿជាក់ប្រាកដក្នុងចិត្តថាគាត់ស្លាប់បាត់ហើយ។ គឺបងថ្លៃនាងបានស្លាប់កាលពីយប់ភ្លៀងធំនោះម៉្លេះ! អញ្ចឹងចុះ...បងថ្លៃដែលឈរជ្រងោក្នុងថ្ងៃនេះ តើជាអ្នកណាវិញ? មនុស្ស ឬមួយជាខ្មោច? មនុស្សដែលដេកស្ងៀមលែងដកដង្ហើមទៅហើយ ពេលដែលក្រោកឡើងវិញនោះគឺប្រាកដជាខ្មោច មិនមែនមនុស្សធម្មតាដូចគេឯងទៀតឡើយ!

នឹកដល់ត្រង់នេះ ភីណាដូចជាព្រឺសម្បុរខ្វាក់ៗ...នាងទទួលអារម្មណ៍ថាភ័យខ្លាចណាស់ គេហដ្ឋានដែលធ្លាប់តែសុខសាន្តកក់ក្ដៅ ប្រែជាមិនគួរឲ្យទុកចិត្តសោះ...នាងស្ទុះក្រោកពីគ្រែ

ទៅរុញទ្វារបិទភ្លាមហើយវិលមកលើគ្រែវិញដណ្តប់ភួយជិត។ អារម្មណ៍រិះគិតដោយតានតឹងថាតទៅទៀតនេះនាងខ្លួនឯងគួរធ្វើម៉េចបើរឿងបងថ្លៃស្រីរបស់ខ្លួនបាត់បង់ជីវិតទៅហើយគឺជាការពិត ប៉ុន្តែទោះនិយាយចេញគ្មានអ្នកណាព្រមជឿផង?។

កំពុងរិះគិត ត្រចៀកផ្ទៀងស្តាប់ឮសម្រិបជើងមនុស្សដើរស្រាលៗខាងក្រៅបន្ទប់ ដាស់តរុណីឲ្យទាញអារម្មណ៍មកវិញ។ នាងផ្ទៀងស្តាប់សូរដឹងថាគឺបងប្រុសឡើងមកដល់ជាន់នេះ ក៏ស្រវាចុះពីគ្រែក្នុងបំណងចេញទៅរកគាត់នឹងអាលពន្យល់ប្រាប់ឲ្យបានច្បាស់លើហេតុការណ៍ទាំងប៉ុន្មានកាលពីយប់ដែលមានភ្លៀងធំនោះ។

ទើបតែឈានចេញពីគ្រែតម្រង់មាត់ទ្វារបន្ទប់បានមួយជំហានប៉ុណ្ណោះ នាងឮសំឡេងបងប្រុសខ្លួននិយាយទូរសព្ទមួយៗតែក្នុងអារម្មណ៍មួហ្មងថា៖

-ដុកទ័រ...! លោកមានប្រសាសន៍ថាប្អូនខ្ញុំគ្មានបញ្ហាអ្វីទេ នាងប៉ះទង្គិចបន្តិចបន្តួច! តែម៉េចក៏ពេលត្រឡប់មកដល់ផ្ទះវិញចេញចរិតប្លែកៗនិយាយស្តីដូចមិនដឹងរឿងសោះ? បើក្បាលនាងមានអីប៉ះពាល់ ដុកទ័រគួរនិយាយប្រាប់ខ្ញុំឲ្យត្រង់?

ភីណាភ្ញាក់។ នាងមិននឹកស្មានថាបងប្រុសនាងមិនត្រឹមតែមិនព្រមស្តាប់ហេតុពិត ថែមទាំងសង្ស័យថាខួរក្បាលប្អូនស្រីខ្លួនឲ្យមានបញ្ហាទៀត។

នារីមួហ្មងក្នុងចិត្តណាស់ ប៉ុន្តែនាងខំទប់ដោយឈរសំកាំងស្តាប់ទ្រឹងនៅពីក្រោយខ្នងគាត់។ ភ្លាមនោះនាងឮបងប្រុសខ្លួនពោលបន្ថែម៖

-ដុកទ័រនៅថាមិនអីទៀត? ភីណាមកដល់ផ្ទះវិញមិនទាន់អីផង ទៅជាមើលលែងស្គាល់បងថ្លៃ! និយាយសម្តីផ្តេសផ្តាសគ្មានក្បាលកន្ទុយ! ខ្ញុំយល់ថាខាងមន្ទីរពេទ្យមិនបានពិនិត្យនាងឲ្យត្រឹមត្រូវសោះ! ខ្ញុំនិយាយត្រង់! ខ្ញុំសង្ស័យថាខួរក្បាលប្អូនស្រីខ្ញុំត្រូវប៉ះទង្គិចចំកន្លែងសំខាន់ណាមួយ ឲ្យទៅជាមានបញ្ហាក៏ថាបាន! មនុស្សនៅសុខៗក្លាយជានិយាយស្តីអត់ដឹងខុសត្រូវ....

ភីណាទទួលអារម្មណ៍ថានាងទ្រាំស្តាប់តទៅទៀតលែងបានហើយ ទើបស្ទុះរឹងបង្ហាញខ្លួនពីមុខបន្ទប់បងប្រុស ដែលកំពុងឈរកាន់ទូរសព្ទនិយាយនៅឡើយ។

យល់វត្តមានប្អូនស្រី លោកកុសលសម្លឹងហើយខំសម្រួលទឹកមុខលាពេទ្យហើយចុចបិទទូរសព្ទ ងាកនិយាយមកកាន់នាងថ្នមៗ៖

-មិនសម្រាកឲ្យស្រួលសិនទៅ? ប្រញាប់ចេញមកធ្វើអ្វី?

ទោះជាលោកកុសលខិតខំសម្រួលឫកពាយ៉ាងណាក៏ភីណាមិនបានរសាយកំហឹងបន្តិចឡើយ នាងខឹងណាស់ ខឹងរហូតដល់រលីងរលោងទឹកភ្នែក។ នាងសម្លឹងបងប្រុសថ្មៃគ្មានព្រិច។ អស់មួយខណៈដែលអភិជនរៀមច្បងទីទើររកពាក្យលួងនាងមិនបាន ទើបនាងពោលសួរដោយអួលណែនដើមក៖

-បង... បងចាត់ទុកថាខ្ញុំវិកលចរិត ថាខ្ញុំឆ្កួតមែនអត់?

លោកកុសលទីទើរ មិនមានឆ្លើយតបថាយ៉ាងណានៅឡើយ។ ហើយក្រមុំភីណាដើរយឺតៗចូលទៅក្បែរគាត់ នាងយំសស្រាក់ផងនិយាយសួរដាច់ៗផង៖

-មិនទាន់អីផង!....បងមិនទាន់ស្ដាប់ខ្ញុំពន្យល់អីបន្តិចផង... ខ្ញុំគ្រាន់តែមានរបួសបន្តិចបន្តួច នាំគ្នាគិតថាខ្ញុំជាមនុស្សឆ្កួតបាត់បង់សតិទៅហើយ?

លោកកុសលរក្សាការស្ងាត់ស្ងៀម ព្រោះគិតថានាងកំពុងរំជួលចិត្ត។ តែភីណាជ្រួញចិញ្ចើមសឹងដល់គ្នា ហើយយំ សស្រាក់ជាងមុនទៅទៀត។ បុរសលូកដៃមកឱបត្រកងស្មានាងហើយលួង៖

-តាំងអារម្មណ៍សិនភីណា!

តែធីតាអភិជនពោលបន្ថែមដោយមុខក្រហមង៉ូវ៖

-តាំងអារម្មណ៍? ខ្ញុំឡប់សតិហើយអ្ហេស៎?! ម៉េចចាំបាច់តាំងស្មារតី? ខ្ញុំភ្លឺស្វាងល្អណាស់! បងទេដែលមិនយល់! គឺគ្រប់គ្នាសុទ្ធតែមិនយល់ ហើយមានះអត់ព្រមស្ដាប់អីសោះ!

លោកកុសលងក់ក្បាលផ្ងក់ៗជាសញ្ញាមិនបដិសេធចំពោះពាក្យសំដីនាង។ គាត់បិទភ្នែកពោលតបមួយៗ៖

-បើគិតថាខ្លួនឯងនៅក្លីស្វាងមែន វាល្អណាស់ហើយ! អូនឯងគួរនិយាយស្តីអីប្រយ័ត្នប្រយែង! នៅនឹងមុខបងវាមិនអីទេ តែនៅមុខគេឯង! អ្នកក្នុងផ្ទះ! បាវព្រាវ! មុខអ្នកបង មុខវិទូគូដណ្តឹងអូន កុំឲ្យយល់ខុសថាយើងមានស្មារតីមិនល្អ!

ភីណាតបភ្លាមដោយមួហ្មងពេញក្នុងចិត្តៈ

-គឺអ្នកទាំងអស់ទេ ដែលមិនដឹងការពិត មិនយល់ការពិតហើយមិនព្រមស្តាប់ការពន្យល់ទៀត? តាមពិតខ្ញុំនិយាយមែន...ប្រពន្ធរបស់បង...គឺ អ្នកបង...អ្នកបង គាត់...គាត់...

នាងក្រមុំមិនទាន់បានបញ្ចប់ប្រយោគផង លោកកុសលពោលកាត់ៈ

-រឿងអ្នកបងហ្នឹងហើយ! នៅខាងក្រោមមិញអូនឯងនិយាយឡូងៗថាគេស្លាប់? មានដឹងខ្លួនអេ្ហះ? ដឹងថាសំដីនេះជ្រុលជ្រួសហួសហេតុប៉ុណ្ណា? បើជាយើង យើងទទួលយកបានអត់ពាក្យចឹងៗ! អ្នកបងគេមិនខឹង មកពីគេចិត្តទូលាយ យល់ថាបងមានប្អូនស្រីតែម្នាក់! ហើយគេក៏គិតថាយើងទើបនឹងចេញពីពេទ្យមក...!

ភីណាជ្រួលច្រាលក្នុងចិត្តណាស់។ កុំថាឡើយឲ្យបងប្រុសយកចិត្តទុកដាក់ស្តាប់ខ្លួននោះ សូម្បីតែប្រើគំនិតពិចារណាបន្តិចក៏គាត់មិនធ្វើដែរ ដូច្នេះពេលនេះសោត ទោះជាខ្លួនរៀបរាប់ពីហេតុការណ៍ដែលប្រពន្ធគាត់ដួលស្លាប់ផ្ទាល់នឹងភ្នែក ក៏គាត់ប្រាកដជាមិនព្រមទទួលយក។ សំខាន់គឺស្រីនោះនៅមិននៅស្លាប់ហើយក៏រស់វិញ។ ឲ្យនាងធ្វើម៉េចទៅ? ម្នាក់ៗអាចថាដូចជាបងប្រុសខ្លួនដែរ គឺកំពុងសង្ស័យថាសរសៃប្រសាទនាងមានបញ្ហាដូចគ្នាក៏មិនដឹង?

ខណៈដែលអារម្មណ៍កំពុងស្មុគស្មាញ នាងឮបងប្រុសនិយាយមកទៀតៈ

-ចង់ញុាំអី? បងCall ហៅមកពីក្រៅឲ្យក៏បាន!

នាងក្រមុំគ្រវីក្បាលយឺតៗៈ

-អត់ឃ្លានទេ!

លោកកុសលតបដោយសម្លឹងមុខប្អូនៈ

-អញ្ចឹង ចូលទៅសម្រាកសិនទៅ កាលណាឃ្លានប្រាប់! បងទៅក្រោមសិនហើយ!

ភីណាសម្លឹងដំណើរបងប្រុសដែលដើរយឺតៗចេញទៅ នាងឮស្នូរដកដង្ហើមធំតានតឹងរបស់គាត់ គឺបង្ហាញភាពស្មុគស្មាញជាងនាងខ្លួនឯងទៅទៀត។ ស្រីស្រស់ដើរយឺតៗទៅកាន់បន្ទប់វិញ បិទទ្វារជាប់រួចឡើងលើគ្រែប្រះខ្នងសម្ងំធ្មេចភ្នែក។ ដោយក្បាលមិនទាន់ជាសះមុខរបួសស្រួលបួលនៅឡើយ ក៏ធ្វើទុក្ខឲ្យឈឺក្បាលជាប់រដឹក។ តែទីបំផុតមាណវីក៏សម្ងំទាល់តែលង់លក់។

ប៉ុន្តែទោះជាលង់លក់ទៅហើយ ក៏អារម្មណ៍ទាំងមូលមិនរសាយចេញពីភាពស្មុគស្មាញងាយទេ។ នាងគេងយល់សប្តិឃើញបងថ្លៃរបស់ខ្លួន បានធ្លាក់រមៀលពីជណ្តើរហូរឈាមច្រមុះមាត់ដេកស្លាប់ច្រងាងកណ្តាលផ្ទះ រឿងហេតុក្នុងសុបិនដូចគ្នាបេះបិទទៅនឹងហេតុការណ៍ពិតប្រាកដនារាត្រីដែលមានភ្លៀងធំនោះ ធ្វើឲ្យនាងក្រមុំភ័យរន្ធត់លាន់មាត់ស្រែករហូតទាល់តែភ្ញាក់ដឹងខ្លួនសាជាថ្មីហើយញ័រដៃជើងបែកញើសស្អិតកណ្តាលចំហាយម៉ាស៊ីនត្រជាក់ ស្មុះស្រវាក្រោកអង្គុយ។

ខណៈដែលមិនទាន់ទាំងបានប្រមូលអារម្មណ៍ ដែលភ័យរន្ធត់ឲ្យបាននឹងនវិញស្រួលបួលផងក៏ស្រាប់តែឮសូរគោះទ្វារយ៉ាងញាប់រួមទាំងឮសំឡេងបងប្រុសនាងប្រកបដោយភាពភិតភ័យ ៖

-បើកទ្វារ!...ភីណា...យ៉ាងម៉េចហ្នឹង បើកទ្វារ?

នាងក្រមុំលើកដៃទាំងពីរជ្រោងសក់ទៅក្រោយ ទាញតម្រង់សំលៀកបំពាក់ស្រួលបួលរួចទើបដើរទៅបើកទ្វារ ទ្វាររបើកលេចរូបបងប្រុសនាងប្រកបដោយទឹកមុខព្រួយបារម្ភ ឃើញនាងភ្លាម គាត់ពោលសួរយ៉ាងញាប់៖

-មានរឿងអី?

តរុណីដឹងថាអម្បាញ់មិញ ការយល់សប្តិឃើញរឿងដ៏ភ័យរន្ធត់ ធ្វើឲ្យខ្លួនរបូតមាត់ស្រែករហូតទាល់តែឮដល់អ្នកផ្ទះ ទើបនាងសម្រួលទឹកមុខតបទៅកាន់គាត់វិញដោយហត់គឃ្លុស៖

-អត់ទេ! ខ្ញុំយល់សប្តិអាក្រក់!

ខណៈនោះស្រាប់តែលេចរូបអ្នកស្រីកុលាបនៅឯមាត់ទ្វារដែរ។ គាត់ញញឹមស្រស់មកកាន់ភីណា។ ប៉ុន្តែនាងក្រមុំវិញសម្លឹងឃើញមុខបងថ្លៃរូបនេះកាលណា នាងបើកភ្នែកធំៗដោយរន្ធត់ចិត្ត ហើយក៏ចេញប្រតិកម្មខ្លាំងៗ៖

-មកធ្វើអី? ចេញ.. ចេញទៅ ចេញភ្លាមទៅ...!

លោកកុសលជ្រួញចិញ្ចើម កាលបើឃើញប្រតិកម្មគួរឲ្យទោមនស្សរបស់នារីជាប្អូនគាត់ពេលដោយមិនសប្បាយចិត្ត៖

-ស្អីគេហ្នឹងភីណា? ក្រែងប្រាប់បងថាស្មារតីភ្លឺស្វាងល្អអ្ហេស៎? បងថ្លៃឯង គេមកមើលឯងល្អជាទេតើ!

នាងក្រមុំតបដោយអារម្មណ៍ច្របូកច្របល់ជ្រួលច្រាលពេញក្នុងចិត្ត៖

-ខ្ញុំមិនចង់ឃើញមុខទេ!...ខ្ញុំឃើញមុខទៀត ខ្ញុំឃើញមុខទៀតច្បាស់ជាឆ្កួតមែនទែនមិនខាន ចេញ ចេញទៅ!

លោកកុសលធ្វើហ៊ឺះ ដើរចេញដោយមួហ្មង ក្រសែភ្នែកចុងក្រោយរបស់ភីណាប្រទះទៅនឹងស្នាមញញឹមលើបបូរមាត់បងថ្លៃស្រី ដែលនាងយល់ថាស្នាមញញឹមនោះត្រជាក់ស្រែង គ្មានលក្ខណៈជាស្នាមញញឹមរបស់មនុស្សធម្មតាសោះ ធ្វើឲ្យនាងក្រមុំទទួលអារម្មណ៍ព្រឺអស់សារពាង្គកាយ ក៏រុញទ្វារបន្ទប់បិទគ្រាំក្រោមការទុចដំណើរង៉ក់ដោយហួសចិត្តរបស់អភិជនជាបង។

នាងស្ទុះឡើងមកលើគ្រែដណ្តប់ភួយជិត ទាំងបេះដូងលោតញាប់រន្ថើន។ មាត់នៅតែរអ៊ូពាក្យដដែលៗដោយបែកញើសស្រោក់ជោកខ្លួន៖

-គាត់មិនមែនមនុស្សទេ មិនមែនទេ គាត់ស្លាប់ហើយ គាត់ស្លាប់បាត់ហើយ មិនមែនមនុស្សរស់ទេ!

នាងឱបដៃទប់ស្កាត់ក្តីរំជួលចិត្ត កណ្តាលចំហាយម៉ាស៊ីនត្រជាក់ដែលត្រជាក់ស្រឹបដូចកំពុងស្ថិតនៅកណ្តាលភ្នំទឹកកក ស្រស់ស្រីយល់ថាបរិយាកាសជុំវិញខ្លួនកាន់តែគួរឲ្យហេងហាងទ្វេឡើង។

នាឡិកាប៉ោលលើជញ្ជាំងវាយ១២អន្លូង...អធ្រាត្របានចូលមកដល់។

ភីណាសម្លឹងជុំវិញខ្លួនដោយញ័ររន្ធត់ នាងស្រវាទូរសព្ទដៃ ដែលផ្ដេកចោលក្បែរខ្លួន ចុចលេខទៅរកវិទូ គូដណ្ដឹងដែលតែងតែឈឺឆ្អាលចំពោះនាង។

កណ្ដាលយប់ស្ងាត់ សំឡេងរបស់អ្នកកំលោះវិទូលាន់មកពីចុងម្ខាងរបៀបងោកងុយះ

-អាឡូ!...អ្នកណានិយាយ?

ស្រស់ស្រីភីណាប្រញាប់ឆ្លើយះ

-វិទូ....អូនណ៎ា! បងកំពុងធ្វើអី ឆាប់និយាយលេងជាមួយអូនទៅ និយាយលេងជាមួយអូនមក! អូនអផ្សុកណាស់ និយាយទៅ និយាយអីក៏បានដែរ។

សំឡេងវិទូសើចខិកពីចុងម្ខាង គេពោលសួរះ

-ម៉េចហ្នឹង? អត់គិតគេងយកកម្លាំងទេ? កណ្ដាលអធ្រាត្រហើយណ៎ា! និយាយលេង?

ភីណាតបដោយភ័យព្រួយះ

-អត់ទេវិទូ អូនគេងអត់លក់! បន្ទប់អូនស្ងាត់ណាស់ បើមិននិយាយលេងជាមួយបងឯងទេ! ខ្លាចខ្លាំងណាស់ អូនទ្រាំមិនបានទេ! បងដឹងអត់ថាផ្ទះអូនគួរឲ្យខ្លាចណាស់! គួរឲ្យខ្លាចមែន!

វិទូស្ងាបហ៊ាមៗដោយងងុយគេង។ តែនរៈខំឆ្លើយតបចំពោះការស្នើសុំរបស់នាងះ

-និយាយអីឥឡូវ! និយាយមកបងនៅស្ដាប់...តែបងបិទភ្នែកនិយាយទេណ៎ា!

-តែអូនគេងអត់លក់ពិតមែន!

-ចុះបងមានថាអី! បងនៅនិយាយជាមួយទេតើ...(នាយប៉ូលិសស្ដីបណ្ដើរស្ងាបបណ្ដើរ)

ភីណាតបដោយមិនសប្បាយចិត្តះ

-អញ្ចឹងបងសម្រាន្តចុះ! ខ្ញុំលែងរំខានហើយ!

វិទូបន្លឺបន្ថែមមកកាន់នាងដោយអាការងោកងុយះ

-អូខេ! ព្រឹកស្អែកទៅលេងអូន!

-ចាំ!

នាងបិទទូរសព្ទដោយទឹកមុខមិនសប្បាយចិត្ត...ប្រះខ្លួនគេង ប៉ុន្តែប្រឹងបិទភ្នែកយ៉ាងណាក៏មិនលក់សោះ ឯពោះក៏ចាប់ផ្ដើមឃ្លានហើយដែរ ត្រូវដល់ពេលលេបថ្នាំទៀត នាងធ្វើម៉េចហ៊ានចេញពីបន្ទប់ចុះទៅផ្ទះបាយរកចំណីទៅ។

ស្រីក្រឡេកទៅឃើញបើកប្រអប់នំដែលមានស្រាប់លើតុសរសេរក្បែរនោះ ក៏ក្រោកទៅលើកមកកំដរពោះ។ ញ៉ាំនំអស់ច្រើនហើយដែរ ឃើញថាបានគ្រាន់បើជាងមុន មិនជាឃ្លានណាស់ណាទេ ប៉ុន្តែភ្នែកឯណេះវិញរឹតតែស្វាងចែស។ កណ្ដាលរាត្រីស្ងាត់សូន្យ ឮតែសូរសំឡេងសត្វរាត្រីចរបន្តគ្នាយំពីក្នុងសួនផ្កា និងភាពងងឹតសព្វទី សភាពភ័យខ្លាចសណ្ឋិតចូលមកក្នុងរាងកាយសាជាថ្មី ។

នាងក្រមុំនឹកដល់រឿងចម្លែករបស់បងថ្លៃខ្លួនដែល នឹកឃើញកាលណាព្រឺព្រួចកាលណោះ នាងនៅតែចិញ្ចឹមចិត្តថាមិនមែនជាមនុស្សទៀតទេ ព្រោះនាងបានឃើញគាត់ស្លាប់ផ្ទាល់នឹងភ្នែក។

នាងស្រវាថ្នាំក្បែរកូនតុដំណេកមករើលេប។ មិនយូរប៉ុន្មានជាតិថ្នាំជ្រាប នាងដឹងថាត្របកភ្នែកខ្លួនចាប់ផ្ដើមទន់ ....

## ភាគទី៥

## វគ្គទី៣

## រឿងរ៉ាវខុសប្រក្រតី

ព្រឹកព្រហាមភីណាភ្ញាក់ដឹងខ្លួន ប៉ុន្តែក្បាលរាងធ្ងន់បន្តិច នាងដឹងថាបណ្ដាលមកពីឥទ្ធិពលជាតិងងុយដែលលាយឡំក្នុងថ្នាំកាលពីយប់។ នាងដើរមករកបន្ទប់ទឹក លុបមុខផង ដឹងផងថាពោះឃ្លានណាស់ នាងរៀបចំផ្លាស់សម្លៀកបំពាក់ ល្មមពេលអ្នកបម្រើចំណាស់ឡើងមករ៉ាយរ៉ាប់៖

-នាងតូច! លោកប្រុសឲ្យចុះទៅក្រោមពិសាបបរ!

នាងក្រមុំតបទាំងសិតសក់បណ្ដើរ៖

-ខ្ញុំចុះទៅឥឡូវហើយមីង!

អ្នកបម្រើសម្លឹងមុខមាណវី ដោយពោលទាំងញញឹមៈ

-នាងតូចផុនមីងដូចជាស្រស់ឡះមុខជាងពីម្សិល!

ភីណាមិនរវល់ពាក្យសរសើររបស់គាត់ តែនាងសួរពីរឿងផ្សេងវិញៈ

-មីងអ្នំា ស្រីម្នាក់នោះមានចុះហូបអាហារទេ?

អ្នកបម្រើជ្រួញចិញ្ចើមដោយមិនយល់សម្ដី គាត់ពោលសួរវិញៈ

-ស្រីម្នាក់ណានាងតូច?

ភីណាតបដោយមុខក្រញូវៈ

-នៅមានស្រីណាច្រើនទៀតនោះ?

អ្នកបម្រើចំណាស់ទំនងជានឹកឃើញ ទើបគាត់ពោលដោយអល់អែកៈ

-នាងតូច! និយាយពីអ្នកស្រីមែនទេ អ្នកស្រីអត់ទាន់ចុះទៅទេ ប៉ុន្មានថ្ងៃនេះអ្នកស្រីមិនសូវពិសាទេ តាមមើលគាត់មានជំងឺអីក៏មិនដឹង។

ភីណានៅស្ងៀមសញ្ជឹងគិត ម៉េចក៏ស្រីម្នាក់នោះមានរឿងចម្លែកៗច្រើនយ៉ាងនេះ ទោះជាយ៉ាងណាក៏អារម្មណ៍មាណវីបានផ្ទៀងទៅលើរឿងអប្បិយជំនឿថាបងថ្លៃខ្លួន កាលបើស្លាប់ហើយរស់ឡើងវិញ បែបនេះគាត់ប្រាកដជាខុសប្លែកពីមនុស្សធម្មតាហើយ នាងពោលទៅកាន់អ្នកបម្រើៈ

-មីងកុំអាលចុះទៅ ចាំពេលខ្ញុំរៀបចំខ្លួនរួចហើយ ចុះទៅទាំងអស់គ្នា!

ភីណារៀបចំខ្លួនរួចរាល់ នាងដើរចេញពីបន្ទប់ជាមួយអ្នកបម្រើសំដៅចុះជណ្ដើរទៅជាន់ខាងក្រោម ដើរកាត់តាមបន្ទប់បងប្រុសខ្លួន ស្រស់ស្រីប្រឹងដើរញាប់ជើងស្មេរ សូម្បីតែដៀងភ្នែកមើលបន្តិចក៏មិនហ៊ានផង។

ពិតដូចពាក្យអ្នកបម្រើនិយាយប្រាប់មែន ចុះមកដល់ខាងក្រោម នាងឃើញបងប្រុសខ្លួននៅបរិភោគម្នាក់ឯង ឯបងថ្លៃគួរឲ្យសង្ស័យរបស់នាងគឺមិនបានចុះមកទេ។ មាណវីដើរទៅអង្គុយ

ក្បែរតុទាំងពោះឃ្លានតាំងតែពីយប់មកម្ល៉េះ នាងនៅរង់ចាំអ្នកបម្រើលើកម្ហូបមកដោយមិនរវល់ចេញស្ដីនិយាយរកបងប្រុសមួយម៉ាត់ ឯលោកកុសលក៏គិតតែពីញ៉ាំដោយមិនរវល់សួរនាំប្អូនដែរ ទំនងមកពីគាត់នៅមិនសប្បាយចិត្តចំពោះកាយវិការភីណាដែលដេញបងថ្លៃនាងកាលពីយប់មិញ។

អ្នកបម្រើលើកថាសម្ហូបមកដល់ តរុណីសម្លឹងម្ហូបលើថាស នាងពោលសួរភ្លាមដោយមិនសប្បាយចិត្ត៖

-យី! មីងអួន! លើកនេះខ្ញុំខាននៅផ្ទះប៉ុន្មានថ្ងៃមីងភ្លេចថាខ្ញុំចូលចិត្តអីហើយមែនអត់??

អ្នកបម្រើចំណាស់តបវិញភ្លាម៖

-ទេអត់នាងតូច! សាច់គោមានអត់ដាច់ទេ ទុកសម្រាប់បាយលុកឡាក់របស់អ្នកនាងតូច តែព្រឹកមិញរកមិនឃើញសោះ សង្ស័យតែមានឆ្មាចូលទេ!

-ផ្ទះយើងមានឆ្កែឆ្មាដែរ? នៅមិននៅមកបាត់សាច់ឆៅ? ស្អែកកុំអញ្ចឹងទៀតណ៎ា!

នាងនិយាយដោយរញ៉ាំរញ៉ូវហើយក្រោកពីចោលតុដើរមកអង្គុយលើសាឡុង អ្នកបម្រើពោលសួរ៖

-នាងតូចមិនត្រូវការពិសាអ្វីផ្សេងទេ?

ភីណាតបវិញដោយទឹកមុខមិនរីករាយ៖

-ខ្ញុំទៅញ៉ាំខាងក្រៅវិញ!

លោកកុសលដែលនៅស្ងៀមមិនចេញស្ដីយូរហើយនោះលូកមាត់ពោលភ្លាម៖

-ខ្លួនទើបតែជាទេ កុំប្រញាប់ដើរទៅក្រៅអី! បើឃ្លានហើយ មានអីចេះតែញ៉ាំសិនទៅ!

ភីណាតបវិញដោយមិនសប្បាយចិត្ត៖

-បើបងមិនឲ្យខ្ញុំទៅទេ មិនបាច់ញ៉ាំក៏មិនបាច់ទៅចុះ!

លោកកុសលសម្លឹងមុខប្អូនដោយអាការមិនពេញចិត្ត គាត់ពោលសួរដោយជ្រួញចិញ្ចើម៖

-ភីណា?

ភីណានៅស្ងៀមទាំងមួហ្មង។ នាងក្រឡេកទៅឃើញទូរសព្ទដោយចៃដន្យនៅលើកូនតុក្បែរដៃ ក៏ប្រញាប់លើកមកចុចស្ដាប់សាកមើលទូរសព្ទនៅប្រើការបានដូចប្រក្រតី???? ចុះម៉េចក៏យប់នោះ ពេលនាងស្លន់ស្លោស្រវាទូរសព្ទរកជំនួយ ទូរសព្ទបែរជាដាច់ប្រើមិនកើតទៅវិញ? ភាពមិនសមហេតុផលចេះតែគាស់កកាយចិត្តនាងឲ្យនឹកមិនអស់ចិត្តទាល់តែសោះ តើពីក្នុងនេះមានអាថ៌កំបាំងអ្វីទេដឹង?

ភីណាដៀងភ្នែកសម្លឹងទៅជើងសាឡុងដែលនាងនៅចាំច្បាស់ថាបងថ្លៃខ្លួនកាលយប់នោះបានដួលទង្គិចយ៉ាងដំណំប៉ះនឹងជើងសាឡុងនេះ នាងក្រោកយឺតៗដើរមកដាក់បង្គុយក្បែរជើងសាឡុង លូកដៃស្ទាប់មើលដោយពិនិត្យពិច័យ ទីនេះពិតជាមានបន្សល់នូវស្នាមរបកមែនបញ្ជាក់ថាកាលបងថ្លៃខ្លួនដួលមកបោកទង្គិចនោះ កម្លាំងទង្គិចពិតជាខ្លាំងក្លាណាស់ គាត់ដាច់ខ្យល់ស្លាប់មិនមែនជាការចម្លែកឡើយ នាងរឹតតែជឿជាក់ថាបងថ្លៃខ្លួនដាច់ដង្ហើមស្លាប់គឺជាការពិត កាលដែលមានបងថ្លៃរស់ជ្រងោម្នាក់ទៀតនេះ គឺប្រាកដជាមានអាថ៌កំបាំង។

នាងចាកចោលការត្រិះរិះ ព្រោះស្នូរម៉ូតូធំរបស់គូដណ្ដឹងលាន់ឮមក។ គឺវិទូមកទទួលនាងទៅញ៉ាំចំណីពេលព្រឹកឯក្រៅផ្ទះ នាងក្រមុំបរិភោគបណ្ដើរត្រិះរិះពីរឿងក្នុងផ្ទះបណ្ដើរ នាងចាប់អារម្មណ៍ឃើញរឿងកាលពីយប់មានភ្លៀងនោះបានត្រូវបំបិទចោលយ៉ាងស្ងាត់បំផុត បងប្រុសខ្លួន អ្នកបម្រើទាំងអស់ គ្មានអ្នកណាមួយដឹងថាកាលយប់នោះ ដែលក្នុងផ្ទះសល់តែភីណានិងបងថ្លៃ បានកើតឡើងនូវរឿងគួរឲ្យរន្ធត់ លុះដល់នាងត្រូវគ្រោះថ្នាក់ចរាចរណ៍ចូលមន្ទីរពេទ្យ។ ពេលត្រឡប់មកផ្ទះវិញ ក៏ស្រាប់តែដឹងថាគេទាំងអស់គ្នាយល់ថាខ្លួនចចេសចាកចេញពីផ្ទះទៅផ្ទះមិត្តភ័ក្ដិទើបបានមានរឿងគ្រោះថ្នាក់ទៅវិញ ឯរឿងដែលមានចោរចូលផ្ទះ និងរឿងដែលបងថ្លៃត្រូវស្លាប់នោះ ទោះជាប្រឹងនិយាយប្រាប់គេក៏គ្មានអ្នកណាព្រមជឿសោះឡើយ ព្រោះថាពេលនេះបងថ្លៃខ្លួនបែរជានៅមានជីវិតរស់ជ្រងោទៅវិញ។ នាងដឹងថាមានតែវិទូទេជាមនុស្សជិតស្និទ្ធរបស់ខ្លួន នាងចង់រៀបរាប់រឿងហេតុទាំងអស់ពីដើមដល់ចប់កាលពីយប់នោះប្រាប់នាយដែរ ប៉ុន្តែនាងដឹងថាបងថ្លៃខ្លួននៅរស់ជ្រងោបែបនេះ បើនិយាយប្រាប់វិទូថាបងថ្លៃខ្លួនស្លាប់នៅយប់នោះ តើធ្វើម៉េចគេអាចជឿសម្ដីនាងកើតទៅ? មធ្យោបាយល្អបំផុតចំពោះមុខ គឺត្រូវតាមឃ្លាំមើលសកម្មភាពរបស់បងថ្លៃខ្លួនបន្តទៀត ហេតុអ្វីបានជាគាត់បែរជានៅរស់ ហើយបានពោលខុសពីការពិតមិននិយាយចេញមកនូវរឿងទាំងប៉ុន្មានកាលពីយប់នោះចេញមកឲ្យគេឯងបានដឹង?

ប្រហែលជាមកពីនាងក្រមុំកំពុងសញ្ជឹងគិតវែងឆ្ងាយភ្លេចនិយាយពីនេះពីនោះជាមួយវិទូ សញ្ជឹងគិតហើយទើបភ្លាមនោះនាងឮអ្នកកំលោះហើបមាត់សួរ៖

-គិតអី? ស្ងាត់ស្ងៀមខុសពីចរិតដើមម្ល៉េះ? សុំស្ទាបថ្ងាសមើល៍! ក្តៅខ្លួនអត់?

នាងក្រមុំភ្ញាក់ហើយគេចខ្លួនពីបាតដៃនាយធ្វើឲ្យបុរសប៉ូលិសញញឹមបញ្ចេញកំនួចស្នេហ៍។ ភីណាខ្លួនប្រមូលអារម្មណ៍មកវិញ និយាយជាមួយអ្នកកំលោះស្រាលៗ៖

- ខ្ញុំស្វាងល្អណាស់! បងឯងទេដែលក្តៅខ្លួន!

ភីណាបម្រុងងាករកអ្នករត់តុនឹងអាលសួររកភេសជ្ជៈ ស្រាប់តែជ្រុលកែងដៃទៅប៉ះក្មេងស្រីជំទង់ម្នាក់ដែលដើរមកជាមួយនឹងសៀវភៅមួយសំណុំធ្វើឲ្យជ្រុះខ្ចាយទៅនឹងដីទាំងអស់។ ធីតាអភិជនប្រញាប់ប្រញាល់ចេញពីកៅអីមកឱនប្រមូលសៀវភៅជាមួយពាក្យសុំទោសញាប់ស្អេក។ ពេលនាងក្រោកមកវិញ ក្មេងជំទង់មិនត្រឹមឈរញញឹមពេញចិត្តជាមួយនឹងកាយវិការគួរសមរបស់ភីណាទេ គឺថែមទាំងបង្ហាញក្រសែភ្នែកស្ងើចសរសើរចំពោះរូបសម្រស់របស់នាងផង។ តរុណីយើងកំពុងថយចូលតុអាហារវិញ ស្រាប់តែឮក្មេងស្រីនោះពោលសួររួសរាយ៖

"បងស្រីស្អាតដល់ហើយ! ដូចជាធ្លាប់ឃើញបងនៅម្តុំនេះ!"

"គឺផ្ទះបងនៅម្តុំនេះដែរ!" នាងបន្តទាំងញញឹមស្រស់ស្រាយ។ វាជាស្នាមញញឹមដែលវិទូខានឃើញជាងមួយសប្តាហ៍មកហើយ។

"តាមពិតស្រីៗចូលចិត្តបានគេសរសើរណាស់ហ្ន៎" វិទូគិតផងលើកកែវកាហ្វេក្រេបស្រូបក្លិនដ៏ឈ្ងុយរបស់វាបណ្តើរផង។ សំឡេងក្មេងស្រីជំទង់លាន់មកវិញ៖

-ផ្ទះណាមួយទៅ! ផ្ទះខ្ញុំនៅកាច់ជ្រុងនោះ បងដែលឃើញខ្ញុំអត់ ផ្ទះលេខ១៥ដែលមានបើក Martនោះ?

-អ្ហូ! បងចូលទិញស្ករកៅស៊ូតែញឹក!

-អញ្ចឹងបានខ្ញុំឃើញបងដូចប្រហែលមុខ!

-ចាំគឺផ្ទះបងនៅរំលងនេះមួយផ្លូវ គឺផ្ទះលេខ៨Dនៅកែងផ្លូវ៣០៣!

ស្រីក្មេងរុះរោយស្នាមញញឹមសន្សឹមៗ។ នាងនិយាយតតាក់តតុប៖

-ផ្ទះលេខ៨Dដែល....ដែល....ដែលនៅជាប់ផ្ទះសម្បូរដើមផ្កាកុលាបសហ្នឹងមែន?

ភីណាបើកភ្នែកគ្រលួង នាងនិយាយដោយត្រេកអរៈ

-មែន! ប្អូនស្រីស្គាល់ច្បាស់មែនហ្ន៎?

វិទូឈ្ងោកមើលទូរសព្ទទុកឲ្យនារីទាំងពីរជជែកគ្នាបន្តដែលនាយយល់ថាជាសកម្មភាពស្រីៗពេញទំហឹងហើយ។ ប៉ុន្តែសភាពមិនប្រក្រតីបានផុសឡើងក្នុងកែវភ្នែករបស់ក្មេងស្រីជំទង់។ ភីណាដែលផ្តោតភ្នែកសម្លឹងគូសន្ទនានាង មានអារម្មណ៍ថាសភាពភ័យបារម្ភមួយបានលេចឡើងលើវង្វង់មុខក្មេងខ្ចីរបស់នារីនោះ បន្ទាប់មកស្រ្តីវ័យក្មេងពោលមួយៗមកកាន់ភីណាៈ

-ផ្ទះនោះធំណាស់ បងអត់ខ្លាចទេអ្ហេស៎?

ភីណាងឿងឆ្ងល់ក្នុងចិត្ត ប៉ុន្តែនាងនៅតែបូញមាត់ញញឹមធ្វើហីៈ

-អត់ផង! ធម្មតា!

ក្មេងស្រីនៅតែបង្ហាញក្តីសង្ស័យលើផ្ទៃមុខ នាងពោលតបមកកាន់ភីណាភ្លាមៈ

-តែ! ខ្ញុំ....ខ្ញុំ...ធ្លាប់ឮម៉ែប្រាប់ថា ផ្ទះនោះមាន...មាន...

នាងកាន់តែនិយាយ សភាពមិនប្រក្រតីកាន់តែកើតមានឡើងលើផ្ទៃមុខក្មេងស្រីជំទង់។ នាងប្តូរចិត្តមិនព្រមនិយាយបញ្ចប់ប្រយោគដែលនោះវិញ ដោយនៅទ្រឹងកណ្តាលទី។ ក្នុងខណៈដែលក្មេងនោះហាក់អល់អែក នាងក្រមុំភីណាបន្លឺសួរភ្លាមៈ

-មានអី? ម្តាយប្អូនគាត់ប្រាប់ថាម៉េចខ្លះ?

ក្មេងស្រីតបភ្លាមលែងបង្អង់ៈ

-ម៉ែថាផ្ទះនោះមានខ្មោច!

ភីណាភ្ញាក់ព្រើត នាងសម្លឹងផ្តោតលើផ្ទៃមុខក្មេងជំទង់ ហាក់ដូចជាមានបំណងចង់បញ្ជាក់ឲ្យច្បាស់ក្នុងចិត្តថាក្មេងនេះកំពុងនិយាយលេងឬមិនមែន? ប៉ុន្តែគ្រាន់តែសម្លឹងទឹកមុខព្រួញបារម្ភរបស់នាង ក៏អាចស្មានដឹងបានថាពាក្យសម្តីដែលនាងនិយាយមិនមែនជាការភូតកុហកឡើយ។ ទោះបីមានអារម្មណ៍ថាស្រៀវឆ្អឹងខ្នង តែក្រមុំអភិជនប្រឹងសម្រួលទៅមុខ ធ្វើយ៉ាង

ណាដូចគ្មានការភ្ញាក់ផ្អើលជាពិសេសទេ ហើយដៀងភ្នែកទៅរកគូដណ្ដឹងដែលឱនលេងទូរសព្ទធ្វើដូចជាមិនបានឮអ្វីទាំងអស់។ ពោលសួរវិញទៅកាន់ក្មេងស្រី៖

-ម្ដាយប្អូន គាត់ថាអញ្ចឹងមែនអ្ហេស៎?

ក្មេងនោះតបវិញទាំងបើកភ្នែកមូលក្លុំសម្លឹងមកភីណា៖

-ចាំ! គាត់ប្រាប់តាំងតែពីបងមិនទាន់រើមកនៅផ្ទះនេះម្ល៉េះ ណាមួយអ្នកម្ដុំនេះបងចាំមើលចុះ ឲ្យតែព្រលប់ឡើងគ្មានអ្នកណាហ៊ានដើរកាត់មុខផ្ទះនោះទេ ចង់ដឹងបងសួរចាស់ៗម្ដុំហ្នឹងទៅ ....ខ្ញុំដល់ម៉ោងទៅរៀន...ខ្ញុំលាសិនហើយ!

នារីវ័យក្មេងតូចមិនទាន់ពោលបញ្ចប់នូវអ្វីដែលខ្លួនចង់និយាយផង ស្រាប់តែរួសរាន់ចាកចេញធ្វើឲ្យធីតាយើងកាន់តែមានអារម្មណ៍ធ្ងន់ពាប់នឹងសកម្មភាពនោះ។ នាងឈ្ងោកសម្លឹងពែងតែក្ដៅទាំងកែវភ្នែកអណ្ដែតអណ្ដូង។ សំឡេងវិទូលាន់មកតិចៗកាត់ផ្ដាច់ការលង់ជ្រៅរបស់នាង៖

-គិតលុយ!

កំលោះប៉ូលិសដឹងថាទោះយ៉ាងណាក៏ពាក្យសម្ដីប៉ុន្មានម៉ាត់របស់ក្មេងស្រីនោះបានបង្កនូវអារម្មណ៍សង្ស័យមួយក្នុងចិត្តភីណាស្រេចទៅហើយ ម្ល៉ោះហើយគ្មានប្រយោជន៍អ្វីដែលត្រូវចំណាយពេលនៅទីនេះទៀតទេ មធ្យោបាយល្អគឺនាំនាងជាមួយបរិយាកាសផ្សេងវិញ។

អង្គុយលើម៉ូតូពីក្រោយវិទូ ស្រីស្អាតនៅតែបន្តសញ្ជឹងគិតពីសម្ដីក្មេងជំទង់ម្ដងហើយម្ដងទៀត នាងមិនយល់ថា ហេតុអ្វីបានជាក្មេងនោះហ៊ាននិយាយសម្ដីរបៀបនោះប្រាប់មកខ្លួន? ខ្មោច? គ្រួសារខ្លួនរើមកនៅប្រមាណជាមួយខែហើយ ម៉េចក៏មិនដែលនឹកនាដល់រឿងទាំងអស់នេះ? ក្មេងនោះស្ដាប់ឮមកពីណាមកឬក៏មានចិត្តចង់និយាយបន្លាចលេង? ក៏ភីណាមិនហ៊ានស្មានដែរ ប៉ុន្តែតាំងតែពីបានឮសម្ដីក្មេងនេះកាលណា នាងចេះតែមានអារម្មណ៍ចម្លែកមិនស្កប់ចិត្តសោះ។ ខណៈនោះដៃរនាងឮសូរវិទូសើចស្រាលៗ នាងងើបមុខសម្លឹងគេ ក៏ឮគេពោល៖

-កំពុងគិតពីសម្ដីក្មេងស្រីនោះនិយាយ?

ភីណាក៏បារម្ភខ្លាចក្រែងអ្នកកំលោះរិះគន់ថានាងមានគំនិតចាស់គំរឹល តែនាងក៏នៅតែចង់សួរ៖

-ចុះបងយល់ថាចម្លែកអត់ដែលនៅសុខៗក្មេងៗមកនិយាយអញ្ជឹងដាក់យើងជាម្ចាស់ផ្ទះ?

វិទូតបមកកាន់នាងក្រមុំវិញដោយទឹកមុខញញឹម៖

-ក្មេងនិយាយក៏និយាយទៅ ប៉ុន្តែផ្ទះអូនមានខ្មោចឬក៏អត់ អូនទេតើដែលជាអ្នកដឹងការពិតនោះ មិនមែនទើបរើមកនៅបានមួយថ្ងៃឯណា?

ភីណាលែងញញឹម ភ្លាមនោះនាងរិះគិតដល់រឿងមិនប្រក្រតីដែលកើតក្នុងរង្វង់គ្រួសារនាពេលថ្មីៗនេះ ពិសេសគឺរឿងបងថ្លៃស្រីរបស់ខ្លួន ស្រស់ស្រីលើកដៃផាត់សក់បណ្ដើរពោលតបបណ្ដើរ៖

-ជួនកាលក៏មានរឿងខ្លះដែលកើតឡើងដោយពិបាកពន្យល់ដែរ! រឿងខ្លះនិយាយទៅពិបាកឲ្យគេជឿណាស់ ប៉ុន្តែវាជាការពិត ដូចយ៉ាងរឿងអ្នកបង....!

ភីណាហៀបនឹងនិយាយចូលដល់រឿងបងថ្លៃរបស់ខ្លួនទៅហើយ នាងស្រាប់តែឈប់មាត់មកវិញព្រោះយល់ថាមិនសមនឹងនិយាយទៀត។ កាយវិការវិទូ និងចរិតរបស់គេគឺមិនចូលចិត្តឲ្យនាងនិយាយផ្ដេសផ្ដាសទេណាមួយកាលពីម្សិលពេលនាងនិយាយរឿងនេះនៅបន្ទប់ធំក្នុងផ្ទះគេក៏នៅទីនោះដែរ។ តើបានប្រយោជន៍អ្វីនឹងនិយាយជាលើកទី២ បើគេគង់តែមិនជឿដដែល? ម៉ូតូដល់មុខផ្ទះល្មមពេលតរុណីសម្រួលសំឡេងនិយាយ៖

-បងទៅចុះ! ខ្ញុំចូលផ្ទះខ្លួនឯងបានហើយ កុំឲ្យជ្រុលម៉ោងធ្វើការ!

វិទូតបវិញដោយអាការប្រញាប់ប្រញាល់៖

-អញ្ជឹងចូលទៅសម្រាកឲ្យស្រួលណ៎ា! កុំគិតអីច្រើនពេក! ចាំបងទូរសព្ទមក!

ភីណាតបដោយទឹកមុខស្ងួត៖

-ចា៎!

ស្រស់ស្រីឈរមាត់ទ្វាររបងសម្លឹងកំលោះគូដណ្ដឹងដែលកំពុងបញ្ឆាជំនិះចេញទៅ គេចេញទៅផុតនាងលើកដៃផាត់សក់ទាំងខ្វល់ខ្វាយហើយដើរយឺតៗចូលទៅក្នុងគេហដ្ឋាន។

ព្រោះតែរំលឹកដល់សម្ដីក្មេងជំទង់នៅឯហាងអាហារ ភីណាងើបមុខសម្លឹងគេហដ្ឋានដែលឈរចង្រ្កង់យ៉ាងធំស្កឹមស្កៃ។ ផ្ទះនេះអាចមានរឿងមិនធម្មតាដូចពាក្យគេនិយាយមែនឬក៏មិនមែន? ភីណាឈ្ងោកមុខដើរយឺតៗចូលទៅក្នុងផ្ទះ ភ្លាមនោះមីងម៉ាប់អ្នកបម្រើរបស់នាងឃ្ងរកន្រ្តកដើរចេញមកដែរ ឃើញភីណាភ្លាមគាត់ក៏ពោលសួរភ្លាម៖

-នាងតូចត្រឡប់មកវិញហើយ? លោកប្រុសផ្ដាំថាបន្ដិចទៀតពេទ្យមកចាក់ថ្នាំជូននាងតូចហើយ!

ភីណាដឹងថាបងប្រុសខ្លួនចេញទៅធ្វើការបាត់ហើយ នាងពោលសួរទៅកាន់អ្នកបម្រើ៖

-មីងទៅផ្សារហើយមែនទេ? កុំភ្លេចទិញសាច់គោណ៎ា!

-ចា៎! នាងតូចមានត្រូវការទិញអ្វីទៀតទេ?